ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ

# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"

# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង

**ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩**

**សវនាការលើកទី៣២**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាតូ គ្រីស្ពារ *(Mr. Matteo Crippa)*

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក យ៉េតចរិយា

លោក វីលៀម ស្មីត *(Mr. William Smith)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទូអាត ហ្វដ *(Mr. Stuart FORD)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្គេក អ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គីមសួន

លោក យុង ផានិត

លោក គឹម ម៉េងឃី

កញ្ញា ទី ស្រ៊ីនណា

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោកស្រី ចេស្ស៊ីកា ហ្វីណែល

*(Ms. Jessica FINELLE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ខ្លឹមសារ

## សាក្សី

**សាក្សី** ៖ ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច

សួរដោយ លោកស្រី ស៊ីលឃី ស្ទូតហ្ស៊ីនស្គី ផ្តើមពី ....................ទំព័រ ១
សួរដោយ កញ្ញា ទី ស្រ៊ីនណា ផ្តើមពី ....................ទំព័រ ៦
សួរដោយ លោក អាឡាំង វែរនេណឺ ផ្តើមពី ....................ទំព័រ ១១
សួរដោយ លោក ការ សាវុត្ថ ផ្តើមពី....................ទំព័រ ២៦
សួរដោយ លោក ហ្វ្រង់ស្វ័រ រូ ផ្តើមពី....................ទំព័រ ៣៦

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ-បារាំង |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |
| លោក យ៉េត ចរិយា | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០១:៥៥]

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលតទៅទៀត ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទមកកាន់ឈើរាងរង្វង់ក្រចកសេះនៅទីនោះ ។

មុននឹងប្រគល់វេទិកានេះទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ អង្គជំនុំជម្រះសូមសួរទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយថា តើត្រូវការប៉ាន់ស្មាន ត្រូវចំណាយពេលវេលាប៉ុន្មានក្នុងការដេញដោល ចំពោះជនជាប់ចោទនៃអង្គហេតុដែលយើងកំពុងធ្វើសវនាការនេះ?

**លោក អាឡាំង វ៉ែនណឺ៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម មេធាវីជាទីគោរព! និយាយដោយត្រង់ទៅគឺវាជាការយល់ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណី ហើយយើងនឹងប្រើប្រាស់ពេលវេលាដែលនៅសល់ពីក្រុមផ្សេង ។ ហើយយើងអាចមានរយៈពេលសែសិបប្រាំនាទី និងម្ភៃនាទីទៀត ដែលយើងអាចសរុបទៅប្រហែលជាមួយម៉ោង ។ ហើយប្រសិនបើអាចធ្វើទៅបាននោះ គឺលោកស្រី-- កញ្ញា ស្ទួត ហ្សីនស្គីប្រើរយៈម្ភៃនាទី ។ ហើយយ៉ាងហោចណាស់ គឺយើងអនុញ្ញាតឲ្យនៅក្នុងក្រុមរបស់យើង គឺចែករំលែកពេលវេលារបស់ខ្ញុំរវាង ទី ស្រ៊ីនណា និងខ្ញុំ ។ ហើយគឺខ្ញុំនឹងធ្វើការបែងចែកពេលវេលារយៈពេលដែលនៅសល់នេះនៅក្នុងចំណោមសហសេវិករបស់ខ្ញុំនេះ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តសូមប្រគល់វេទិកាទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរដើម្បីបន្តធ្វើការដេញដោលចំពោះអង្គហេតុដែលកំណត់ធ្វើសវនាការនេះចំពោះជនជាប់ចោទ ។ សូមអញ្ជើញ ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

អរុណសួស្តី សូមអរគុណលោកប្រធាន អរុណសួស្តីភាគីទាំងអស់ ។ ខ្ញុំគិតថា អង្គជំនុំជម្រះយល់ស្របទៅនឹងអ្វីដែលសហសេវិករបស់ខ្ញុំបានលើកឡើង ខ្ញុំអាចចំណាយពេលរយៈម្ភៃនាទីទៀតដែលនៅសល់ពីក្រុមផ្សេង ។ ហើយខ្ញុំសូមចាប់ផ្តើមការតាំងសំណួរនៅព្រឹកនេះ ហើយខ្ញុំសូមបន្តនៅកន្លែងដែលខ្ញុំបានឈប់កាលពីម្សិលមិញទាក់ទងទៅនឹងអ្នកសួរចម្លើយស្ត្រី ។

[០៩:០៦:២០]

**ស៖** លោកបានពន្យល់ប្រាប់កាលពីម្សិលមិញថា អ្នកសួរចម្លើយស្ត្រីនោះ ទទួលបានការអប់រំ ហើយពួកគេបានចូលរួមនៅក្នុងការសួរចម្លើយរបស់អ្នកសួរចម្លើយចាស់ៗ ។ សំណួររបស់ខ្ញុំនោះគឺថា ថាតើអ្នកសួរស្រីនេះគឺគាត់ចូលរួមនៅការអប់រំ សួរចម្លើយនោះញឹកញយប៉ុនណា? ហើយគាត់ចូលរួមវគ្គអប់រំរយៈពេលប៉ុន្មាន ដើម្បីគាត់អាចចាប់ផ្តើមការងាររបស់គាត់ជាអ្នកសួរចម្លើយបាន?

**ជនជាប់ចោទ៖**

**ឆ៖** ជម្រាបប្រសាសន៍កញ្ញាមេធាវី! ទីមួយកម្មាភិបាលស្រី សួរចម្លើយស្រីនេះ អត់បានរៀនសូត្រពីខ្ញុំទេ ។ ទីពីរ គេទៅមើលអ្នកផ្សេងទៀតសួរចម្លើយ ហើយគេក៏ចាប់ផ្តើមសួរទៅ ។ នៅក្នុងពេលដែលសួរចម្លើយនេះហើយ ក្រោយមកខ្ញុំក៏យកគេទៅអប់រំតាមសភាពការណ៍នយោបាយនៃការសួរចម្លើយនៃទិសសួរចម្លើយ ។ ដូចគេដូចឯង ខ្ញុំអប់រំពីអី ឯកសារនៅមានសល់ទេ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ។

**ស៖** ខ្ញុំនឹងបញ្ជាក់សំណួរខ្ញុំឲ្យបានច្បាស់ មុនពេលដែលពួកគេចាប់ផ្តើមសួរចម្លើយ ថាតើអ្នកសួរចម្លើយស្ត្រីនោះ គាត់ចូលវគ្គការអប់រំហ្នឹងប៉ុន្មានដងដែរដើម្បីធ្វើការចាប់ផ្តើមការងារសួរចម្លើយរបស់គាត់?

**ឆ៖** ខ្ញុំសូមបញ្ជាក់ម្តងទៀត ខ្ញុំបានជម្រាបហើយថាពួកនាងៗអស់នោះ អត់បានរៀនសូត្រអំពីបច្ចេកទេសសួរចម្លើយផ្ទាល់ពីខ្ញុំទេ ។

**ស៖** សូមអភ័យទោស នេះមិនមែនជាអ្វីដែលខ្ញុំលើកឡើងនោះទេ ។ លោកបានប្រាប់យើងថា អ្នកសួរចម្លើយទាំងអស់នោះ គឺបានចូលរួមនិងទៅសង្កេតអ្នកសួរចម្លើយចាស់ៗដើម្បីសិក្សា ហើយខ្ញុំចង់ដឹងថា តើអ្នកសួរចម្លើយស្ត្រីទាំងអស់នោះចូលរួមនៅក្នុងការពិនិត្យ សង្កេតមើលអ្នកសួរចាស់ៗនោះប៉ុន្មានដងដែរ? គាត់ចូលរួមធ្វើការពិនិត្យរយៈពេលប៉ុន្មាន ទើបគាត់ចាប់ផ្តើមការងារ? ខ្ញុំមិនមែនសួរថាគាត់ទៅទទួលការអប់រំពីលោកនោះទេ?

**ឆ៖** អរគុណនេះ ប្រហែលជាយើងស្តាប់គ្នាមិនបានរឿងបកប្រែទេ ខ្ញុំយល់ហើយ ។ ខ្ញុំមិនចាំថាគេទៅពិនិត្យមើលពីអ្នកសួរចម្លើយចាស់ៗប៉ុន្មានថ្ងៃទេ ។ សូមជម្រាបប៉ុណ្ណេះ ។

[០៩:០៩:៥២]

**ស៖** តើលោកអាចធ្វើការសន្និដ្ឋានទៅមើល ថាតើពួកគេទៅសង្កេតម្តង?ដប់ដង? ហាសិបដង? ឬក៏មួយរយដង?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! ប្រហែលជាប្រាំដងយ៉ាងច្រើន ។

**ស៖** សូមអរគុណច្រើន ។ តើគេប្រាប់លោកអំពីអារម្មណ៍ ឬក៏ភាពស្ទាក់ស្ទើរ ដែលវាមានចំពោះអ្នកស្ទួរចម្លើយស្ត្រីទាំងអស់នេះ ក្នុងការដែលគេហៅឲ្យទៅសួរចម្លើយដែរឬទេ? តើលោកបានទទួលថា ពួកអ្នកសួរចម្លើយស្ត្រីនោះ គាត់មានអារម្មណ៍ស្ទាក់ស្ទើរ? ហើយតើគេមានប្រាប់លោកអំពីបញ្ហាហ្នឹងដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! ខ្ញុំអត់មានការទាក់ទងផ្ទាល់ជាមួយនឹងកម្មាភិបាលស្រីសួរចម្លើយស្រីនេះទេ អ្នកដែលទទួលខុសត្រូវយកទៅដាក់តាមបញ្ជាខ្ញុំហ្នឹង គឺមិត្តហ៊ៃ ។ ហើយក្នុងនុំងប្រពន្ធគេមិត្តម៉ុត ជាប្រធានកម្មាភិបាលសួរចម្លើយស្រីហ្នឹងស្រាប់ ។ ដូច្នេះ គេអ្នកក្តាប់សតិអារម្មណ៍ ខ្ញុំធ្វើឲ្យតែបានស្រីៗចូលទៅក្នុងអង្គភាពសួរចម្លើយប៉ុននុំង ខ្ញុំស្កប់ចិត្តហើយ ។

**ស៖** ខ្ញុំនឹងចូលទៅដល់ចំណុចមួយទៀត ។ តើលោកចាំអ្នកសួរចម្លើយឈ្មោះ តួច អ្នកសួរចម្លើយ តួច ដែរឬទេ? តើលោកស្គាល់អ្នកសួរចម្លើយមួយនេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! បញ្ជាក់បន្តិចមើល តួច ហ្នឹងស្រី ឬប្រុស? ខ្ញុំមិនចាំទេ ។

**ស៖** គាត់គឺជាអ្នកសួរប្រុស ហើយក្រោយមកគេឃុំគាត់នៅស-២១ ។

**ឆ៖** ខ្ញុំមិនស្គាល់ទេ ជម្រាបប្រសាសន៍ ខ្ញុំមិនស្គាល់ទេ ។

**ស៖** លោកដឹងថាសាក្សីដែលនិយាយ បានលើកឡើងថាគាត់ត្រូវបានគេចោទអំពីការរំលោភផ្លូវភេទ ហើយត្រូវបានគេចាប់ ហើយក្រោយមកគឺគាត់សម្លាប់ខ្លួនឯង ។

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា ឈ្មោះ តួច ក៏ខ្ញុំមិនស្គាល់ ។ បាតុភាពនៃរឿងអ្នកសួរប្រុសទៅរំលោភលើអ្នកទោសស្រី ក៏ខ្ញុំមិនដឹង ។ ហើយរឿងអ្នកសួរប្រុសនេះធ្វើអត្តឃាដខ្លួនឯងខ្ញុំមិនដឹងទេ នេះជម្រាបដោយត្រង់ ខ្ញុំអត់ដឹង ។

**ស៖** សំណួរបន្ទាប់របស់ខ្ញុំ គឺអំពីការងារចម្បងរបស់លោក គឺការងារធ្វើចំណារនិងអានចម្លើយសារភាព ។ ខ្ញុំចង់ដឹងថា តើលោកបានអានចម្លើយសារភាពរបស់អ្នកសួរចម្លើយដែលត្រូវបានគេឃុំនៅស-២១ ដែរឬទេ?

[០៩:១៥:២៦]

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! អាន ពិតជាបានអាន ក៏ប៉ុន្តែវាភ្លេចអស់ទៅហើយ ពេលដល់ពេលនេះ ។

**ស៖** ដូច្នេះ ខ្ញុំចង់តទល់ជាមួយលោកទាក់ទងទៅនឹងខ្លឹមសារនៃចម្លើយសារភាពមួយចំនួននេះ ។ យើងឃើញមានចម្លើយសារភាពរបស់ ញ៉ូ កាន់ដា, ជា ខាត់, វ៉ូត ថេង និង ជា ម៉ី ។ តើលោកស្គាល់អ្នកសួរចម្លើយម្នាក់ក្នុងចំណោមអ្នកទាំងបួននេះដែរឬទេ? ខ្ញុំសង្ឃឹមថា ខ្ញុំប្រកបឈ្មោះនោះបានច្បាស់ ។

**ឆ៖** ខ្ញុំមិនស្គាល់ទេៗ ។

**ស៖** ចម្លើយសារភាពត្រូវបានវិភាគដោយ ដេវីត ឆេនដ៍ល័រ ហើយគាត់បានបញ្ជាក់ថា ចម្លើយសារភាពនោះ គឺបានសារភាពថា មានការរំលោភផ្សេងៗ ។ តើលោកធ្លាប់អានចម្លើយសារភាពរបស់អ្នកសួរចម្លើយដែរឬទេ ដែលគាត់សារភាពថា គាត់បានប្រព្រឹត្តការរំលោភអីផ្សេងៗ? តើលោកធ្លាប់អានចម្លើយសារនោះដែរឬទេ?

**ឆ៖** សូមបញ្ជាក់ថា បើសិនជាលើចម្លើយសារភាពនោះ ខ្ញុំមានចារ អាហ្នឹងវាច្បាស់ថា ខ្ញុំបានអាន បើខ្ញុំគ្មានបានចារ ហើយអត់បានសរសេរបន្តិចសោះ ខ្ញុំសន្មតថា ប្រហែលជាខ្ញុំមិនបានអាន ។ ព្រោះខ្ញុំមិនយកចិត្តទុកដាក់ ដូច្នេះសូមកញ្ញាពិនិត្យមើលចម្លើយនុ៎ង តើខ្ញុំមានចារទេ?

**ប្រធានអង្គជំនុំ៖**

មេធាវីក្រុមពីរ រំឭកឡើងវិញថា ចម្លើយសារភាពដោយដែលបានមកពីការបង្ខិតបង្ខំ ឬក៏ការធ្វើទារុណកម្ម មិនអាចធ្វើអាចមូលដ្ឋានក្នុងការសួរដេញដោលនេះបានទេ ។ លើកលែងតែពាក់ព័ន្ធជាមួយនឹងអំពើដែលធ្វើទារុណកម្មមនុស្ស ដូចយើងបានណែនាំរួចហើយ ។ អ៊ីចឹង មិនអាចផ្អែកលើមូលដ្ឋានលទ្ធផលនៃចម្លើយសារភាព ដែលទទួលរងដោយទណ្ឌកម្មយកមកដេញដោលបានទេ ។ សូមមានការប្រយ័ត្នលើចំណុចនេះ ។

**លោកស្រី ស៊ីលឃីស្ទត ហ្សិនស្ដី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមពន្យល់ថា ខ្ញុំមិនប្រើប្រាស់ចម្លើយនេះ ក្នុងគោលបំណងនោះទេ ខ្ញុំគ្រាន់តែចង់សួរថា តើគាត់បានអានចម្លើយសារនោះដែរឬទេ? ហើយគាត់ជឿថាចម្លើយនោះត្រឹមត្រូវ ឬមិនត្រឹមត្រូវ? ហើយថាគាត់មានធ្វើចំណារ ដើម្បីធ្វើការស៊ើបអង្កេតលើករណីផ្សេងៗ និងបទល្មើសផ្សេងៗដែរឬទេ? ឬក៏គាត់បានជឿដែលឬទេថា ការសារភាពរបស់អ្នកទាំងអស់នោះ គឺមិនត្រឹមត្រូវទេ? ដូចករណីចម្លើយសារភាពរបស់ KGB និងCIA ផងដែរ ។

ដូច្នេះការឆ្លើយតបរបស់ជនជាប់ចោទនោះ គឺគ្រាន់តែចង់ដឹងថា តើគាត់យល់ទៅលើខ្លឹមសារថាវាត្រឹមត្រូវ ឬមិនត្រឹមត្រូវនោះ វាត្រឹមកម្រិតណា? នេះជាគោលបំណងដែលខ្ញុំចង់សួរ ។ យើងបាន

ឮហើយថា ជនជាប់ចោទមិនអានចម្លើយសារភាពទាំងអស់នោះទេ ។ ហើយគឺចម្លើយសារភាពនោះ គឺទាល់តែគាត់បានធ្វើចំណារ ទើបគាត់បានអាន ។ តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយ ។

[០៩:១៩:០២]

**ស៖** ខ្ញុំសូមចូលទៅដល់ចំណុចមួយទៀត ហើយខ្ញុំនឹងចាប់ផ្តើមពីសំណួរក្នុងន័យទូទៅ ហើយបន្ទាប់មកខ្ញុំនឹងចូលទៅដល់ចំណុចដែលខ្ញុំចង់ដឹងអំពីប្រតិបត្តិការរបស់ស-២១ ។ សំណួរទូទៅរបស់ខ្ញុំនោះគឺ តើវាត្រឹមត្រូវដែរឬទេ ក្នុងការលើកឡើងថា បទល្មើសផ្នែកខាងសីលធម៌នោះ គឺវាត្រូវបានគេដាក់ទោស? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយ ។

**ស៖** សូមអរគុណ ។ តើលោកឯកភាពទេ ថាការរំលោភ ឬក៏ការបំពានលើផ្លូវភេទនោះ គឺជាបទល្មើសធ្ងន់ធ្ងរជាង? ហើយត្រូវបានគេដាក់វិន័យធ្ងន់ធ្ងរជាងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យជាទូទៅនោះ?

**ឆ៖** ត្រូវហើយ ។

**ស៖** តើលោកឯកភាពទេថា ទៅតាមមាគ៌ារបស់បក្សនៅក្នុងការចែងថា ការដាក់ឈើចូលទៅក្នុងយោនីនោះ គឺជាកំហុសសីលធម៌? ហើយជនដែលដល់ គឺនឹងត្រូវទទួលវិន័យយ៉ាងធ្ងន់ធ្ងរ? ខ្ញុំនិយាយអំពីគោលនយោបាយទូទៅ តើលោកឯកភាពដូច្នេះទេ?

**ឆ៖** បញ្ហានេះ ខ្ញុំសូមរក្សានៅស្ងៀម ។

**ប្រធានអង្គជំនុំ៖**

សំណួរនេះច្រំដែល ហើយសូមដូរសំណួរផ្សេង ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សឺនស្គី៖**

ខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យបានច្បាស់ថា ការរុកបញ្ចូលឈើទៅក្នុងយោនីនោះ គឺជាកំហុសមួយធ្ងន់ធ្ងរនៅក្នុងគោលនយោបាយទូទៅ ។

**ស៖** ឥឡូវនេះខ្ញុំបន្តទៅមុខទៀត ខ្ញុំចង់រំឭកឡើងវិញថា លោកបានប្រាប់អង្គសវនាការថា លោកមិនបានដឹងថា ការដាក់ឈើបញ្ចូល រុកចូលទៅក្នុងយោនីនោះ គឺជាបទល្មើសដែលត្រូវបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ ។ ពីព្រោះកាលពីសប្តាហ៍មុនលោកបានពន្យល់ថា លោកមិនបាន

ដឹងអំពីច្បាប់ឲ្យបានពិតប្រាកដទេនៅពេលនោះ ទើបតែឥឡូវលោកយល់ថានោះ គឺជាបទល្មើស ។

ដូច្នេះសំណួររបស់ខ្ញុំនោះសួរថា តើហេតុអ្វីដែលបានជាលោកមិនបានដឹងថានោះ គឺជាបទល្មើស ទោះបីជានៅក្នុងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានោះ គឺមានភាពតឹងរឹងណាស់? សំណួររបស់ខ្ញុំ គឺថាហេតុផលនៃការប្រព្រឹត្តដូច្នេះមកលើខ្មាំង មកលើអ្នកទោសដែលត្រូវបានគេចាត់ទុកថាជាខ្មាំងនោះ តើអំពើនោះមិនត្រូវបានគេចាត់ទុកថា ជាបទល្មើសទេឬ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! ខ្ញុំអត់បានរៀនក្រមព្រហ្មទណ្ឌច្បាប់ខ្មែរយើងទេ ដូច្នេះខ្ញុំអត់ដឹងរឿងហ្នឹង ខ្ញុំបានរាយការណ៍ជូនអង្គសវនាការថា មេខ្ញុំក៏ប្រហែលជាមិនដឹងដែរ ។ ដូច្នេះ ខ្ញុំសូមគ្រាន់តែបញ្ជាក់តែប៉ុណ្ណេះឯង ។ ឯចំណែកមាគ៌ាបក្សអត់បានចែងបញ្ហានេះទេ ។ នេះគឺសូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** តើលោកមានបានដឹងថា នោះគឺជាអំពើខុសទេ ក្នុងលក្ខណៈជាទូទៅនោះ?

**ឆ៖** សូមទោស ខ្ញុំសូមមិន-- រក្សាសិទ្ធិនៅស្ងៀម ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្តី៖**

ខ្ញុំមិនមានសំណួរទៀតទេ ទាក់ទងទៅនឹងប្រធានបទនេះ ។ ដូច្នេះ ខ្ញុំនឹងប្រគល់វេទិកានេះទៅឲ្យសហសេវិករបស់ខ្ញុំ ។ សូមអរគុណ ។

[០៩:២៤:២៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ។

**សួរដោយកញ្ញា ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន ។ ជាបឋមសូមគោរពលោកប្រធាន និងអង្គសវនាការទាំងមូល ។ ខ្ញុំមានសំណួរមួយចំនួនតូច ដើម្បីសួរទៅជនជាប់ចោទ ។

**ស៖** សំណួរទីមួយរបស់ខ្ញុំទាក់ទងទៅនឹងការកម្ទេចជាលក្ខណៈទ្រង់ទ្រាយធំ នៅដំណាក់កាលចុងក្រោយ ។ នាងខ្ញុំចង់សួរថា តើការកម្ទេចអ្នកទោសនៅមន្ទីរស-២១ ជាលក្ខណៈទ្រង់ទ្រាយធំហ្នឹងមានចំនួនប៉ុន្មាននាក់?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញាមេធាវី! ការកម្ទេចចុងក្រោយនេះ ដែលធំជាងគេ បើតាមខ្ញុំចាំមិនចាំតួលេខច្បាស់លាស់ទេ ប្រហែលជាបីរយ លើសខ្វះបន្តិចបន្តួច ។

**ស៖** អ៊ីចឹងខ្ញុំសូមអរគុណ និងសូមបន្តសំណួរទីពីរ ។ សំណួរទីពីរ ខ្ញុំចង់សួរទាក់ទងទៅនឹងដំណាក់កាលចុងក្រោយដែរ នៅដើមខែមករា ឆ្នាំ១៩៧៩ ។ នៅដំណាក់កាលនុ៎ង តើលោកអាចចាំបានទេថា នៅក្នុងដំណាក់កាលហ្នឹងមានការ អ្នកទោសដែលនៅសេសសល់នៅក្នុងមន្ទីរស-២១ ដែលត្រូវបញ្ជូនយកទៅសម្លាប់ហ្នឹង មានចំនួនប៉ុន្មាននាក់ដែរ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! ខ្ញុំអត់បានគិតដល់តួលេខទេ ខ្ញុំដឹងតែធ្វើម៉េចបទបញ្ជាខ្ញុំ ដែលខ្ញុំនាំពាក្យពីលើមកត្រូវបានគេអនុវត្តពេញលេញ ។ បានន័យថា គ្មានអ្នកទោសណាម្នាក់នៅសល់ លើកលែងតែបួននាក់ដែលខ្ញុំសុំទុក ដែលខ្ញុំសុំអចិន្ត្រៃយ៍ទុកសម្រាប់សួរតទៅទៀត គឺយុទ្ធជន ពួកអង្គភាព យ-៨ ។

ខ្ញុំសូមបញ្ជាក់ជូនកញ្ញាបន្តិចថា ពួកយុទ្ធជនអង្គភាព យ-៨ ហ្នឹង មានគ្នាបួននាក់ ។ ពួកយុទ្ធជនអង្គភាពយ-៨ ហ្នឹងទាក់ទងនឹងការបាញ់ភ្ញៀវបរទេសគឺបាញ់ *រីឆាត ប៉ែកម៉ាន់*-- អឺ បាញ់ពួកអ្នកដែលមកជាមួយ *រីឆាត ប៉ែកម៉ាន់, អេលីហ្សាប៉ែត ប៊ីឃ័រ* ហើយនិង *ម៉ាល់ ខមខូលវែល* ឈ្មោះប្រហែលអ៊ីចឹង ។ នៅពេលនុ៎ងហើយ ដែលគេចាប់ពួកហ្នឹងមកឲ្យ ហើយខ្ញុំត្រូវការចង់សួរចម្លើយ ខ្ញុំសុំទុកបួននាក់នុ៎ង ។ ដូច្នេះ អ្នកទោសសម្រាប់សួរនៅសល់បួន ខ្ញុំចាំតែប៉ុណ្ណឹង ។

[០៩:២៧:៣៨]

**ស៖** ចុះលោកមាន នៅក្នុងស្ថានភាពពេលនុ៎ង តើលោកអាចគ្រប់គ្រងនៅមន្ទីរស-២១ ទាក់ទងទៅនឹងការដែលអ្នកទោស ដែលត្រូវបានសម្លាប់នៅតាមបន្ទប់នៃមន្ទីរ ស-២១ហ្នឹង តើលោកអាចមានចាំថា តើមានចំនួនប៉ុន្មាននាក់ ដែលបានសម្លាប់នៅលើគ្រែនៃបន្ទប់នីមួយៗនៅក្នុងមន្ទីរ ស-២១?

**ឆ៖** អរគុណកញ្ញាដែលលើកបញ្ហានេះមកសួរ ។ មានតែពួក យ-៨ បួននាក់ប៉ុណ្ណោះ ដែលអ្នកសួរគេកម្ទេចដោយ*បីយ៉ូណែត*ចាក់ ហើយស្លាប់នៅលើគ្រែ ។ ហើយខ្ញុំរត់ចេញទៅនៅម៉ោងពីររសៀលថ្ងៃ៧ មករា ១៩៧៩ ចោលសពនៅហ្នឹងបួននាក់ ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមបន្តសំណួរខ្ញុំតទៅទៀត ទាក់ទងទៅនឹងដំណាក់កាលចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ តើលោកអាចចាំបានទេនៅក្នុងដំណាក់កាលចុងក្រោយហ្នឹង លោកបានដឹងជាមុនដែរឬទេ ទាក់ទងទៅនឹងស្ថានភាពនោះ?

**ឆ៖** ខ្ញុំរត់ទៅមានតែខោខ្លី ហើយនិងស្បែកជើង ហើយនិងអាវដៃខ្លីទេ ។ នេះជម្រាបដោយត្រង់ដូច្នេះ ខ្ញុំគ្មានដឹងអីទាំងអស់ គេអត់ប្រាប់ខ្ញុំទេ គេអត់ប្រាប់ខ្ញុំថា ត្រូវការរត់ទេ ។

**ស៖** ប៉ុន្តែតើលោកអាចបានដឹងជាមុនពីស្ថានភាពហ្នឹង ដូចជាតាមរយៈសារព័ត៌មានផ្សេងៗ ក៏ដូចជាតាមវិទ្យុផ្សេងៗ ដែលអាចថាមានស្ថានភាពហ្នឹងកើតឡើង ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** អរគុណកញ្ញាដែលលើកសំណួរនេះមកសួរខ្ញុំ ។ គេផ្សាយវិទ្យុ ប៉ុល ពត សម្ដី ប៉ុល ពត តែម្ដង ថាវៀតណាម អើ!យើងហៅពាក្យតាមគេជំនាន់នុំងចោះ “ថាយួនវាអាចចូលជ្រៅ សូមមិត្តទាំងជិត ទាំងឆ្ងាយ គាំទ្រកម្ពុជាប្រជាធិបតេយ្យតទៅទៀត” ខ្ញុំឮសេចក្ដីថ្លែងការណ៍នោះ សេចក្ដីអំពាវនាវនោះ ក៏ប៉ុន្តែខ្ញុំអត់យល់ មិនស្មានថា ប៉ុល ពត ចាញ់រត់ចោលភ្នំពេញទេ ខ្ញុំស្មានតែចូលជ្រៅដូចពីមុន នេះខ្ញុំឮអាហ្នឹងមួយ ។ ក៏ប៉ុន្តែកុំភ្លេចថា ថ្ងៃ៦ មករា ប្រហែលជាម៉ោងប្រាំបួន ខ្ញុំត្រូវគេហៅទៅធ្វើការនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ។ ខ្ញុំទៅមិនជួប ពូនួន គឺ នួន ជា បែរជាទៅជាជួប បងហែម គឺ ខៀវ សំផន ទៅវិញ ខ្ញុំរារែកមិនចង់ចូល ។ ចូលទៅដល់ បងហែម គាត់មិនទាំងនិយាយរកខ្ញុំផង ។ ខ្ញុំអង្គុយកៅអីមុខគាត់ហ្នឹង ស្ដាប់គាត់ឧទ្ទេសនាមថា យួន ខ្ញុំប្រើពាក្យ “យួន” ទៅចុះ វាចូលមកជ្រៅមែន ក៏ប៉ុន្តែកុំភ័យកងមិត្ត រឿន និងកងមិត្តសាន នៅទប់ ។ ខ្ញុំជឿគេ ជឿ អត់មានទឹកនាអីទេ ខ្ញុំគិតតែពីដេកតទៅទៀត ដូចខ្ញុំបានជម្រាបរួចមកហើយ ថាខ្ញុំវាតក់ស្លុត រហូតដល់ដេក គិតតែពីដេក នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** អ៊ីចឹង ខ្ញុំសូមអរគុណនិងសូមបន្តសំណួរខ្ញុំមួយសំណួរទៀត ។ ទាក់ទងទៅនឹងដំណាក់កាលចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យដែរ ដូចលោកបានរៀបរាប់អម្បាញ់មិញហើយថាលោកក៏បានដឹងនិងបានឮការផ្សាយវិទ្យុទាក់ទងទៅនឹងទ័ពវៀតណាម នឹងចូលមកដើម្បីផ្ដួលរំលំរបបកម្ពុជាប្រជា-ធិបតេយ្យ លោកបានដឹងខ្លះដែរ ។ ចុះនៅក្នុងដំណាក់កាលពេលនុំង លោកមានដែលគិតថា លោកចង់ដោះលែងអ្នកទោសដែលនៅសេសសល់នៅមន្ទីរស-២១ឱ្យរួចខ្លួន ពីព្រោះថា-- តើលោកមានបំណងចង់ដោះលែងដែរឬទេ? ព្រោះពេលហ្នឹងវាគឺជាស្ថានភាពមួយដែលច្របូកច្របល់ ដែលលោកគិតថាមើលទៅវាជាស្ថានភាពមួយដែលច្របូកច្របល់ តាមទស្សនៈរបសលោកដែលលោកគិតថាអម្បាញ់មិញហ្នឹងគឺវាមានលក្ខណៈច្របូកច្របល់ ។

ហើយអ៊ីចឹង តើលោកមានបានគិតដល់ការដោះលែងអ្នកទោសដែលនៅសេសសល់នៅក្នុងមន្ទីរ ស-២១ ឱ្យមានសេរីភាពឡើងវិញទេ? ពីព្រោះកន្លងមកដែលលោកតែងតែលើកឡើងថា រាល់ការបញ្ជារបស់ថ្នាក់លើដែលបញ្ជាឱ្យលោកសម្លាប់មនុស្ស ឬក៏បញ្ជាឱ្យលោកកម្ទេចអ្នកទោសនៅក្នុងមន្ទីរស-២១ នោះ គឺលោកមិនពេញចិត្តទៅនឹងការបញ្ជានុំងទេ ។ ហើយការងារដែលលោកធ្វើកន្លងមកនៅក្នុងមន្ទីរ

ស-២១ហ្នឹង ក៏លោកពុំពេញចិត្តទៅនឹងការងារហ្នឹងដែរ គឺធ្វើទាំងបង្ខំ បើសិនជាលោកមិនធ្វើគឺគេនឹងសម្លាប់លោក ប្រពន្ធកូនលោក និងក្រុមគ្រួសារលោក មិនថាប្រពន្ធកូនលោកដោយផ្ទាល់ ហើយក៏មិនថា ប្រពន្ធកូនក្រុមគ្រួសារ ដែលជាសាច់ញាតិដូចជា ឪពុកម្ដាយលោកអី ។ ហើយអ៊ីចឹង តើលោកមានគិតដល់ដំណាក់កាលហ្នឹងថាតើនេះ គឺជាដំណាក់កាលមួយនៃការដួរលំរបបកម្ពុជាប្រជាធិបតេយ្យហើយ ។ អ៊ីចឹង វាជាឱកាសមួយដែលលោកគិតថា នឹងអាចជួយស្រោចស្រង់អ្នកទោសនៅមន្ទីរស-២១ អាចដោះលែងអ្នកទោសនៅមន្ទីរស-២១ ដែរឬទេ?

[០៩:៣២:៥៧]

**ឆ៖** ជម្រាបប្រសាសន៍កញ្ញាមេធាវី! ខ្ញុំសូមបញ្ជាក់ឡើងវិញ ក្នុងការដែលខ្ញុំឮសេចក្ដីអំពាវនាវរបស់ ប៉ុល ពត ខ្ញុំស្ដីកណាស់ មិនទាន់ជឿថាកម្ពុជាប្រជាធិបតេយ្យចាញ់គេទេ ខ្ញុំនៅជឿលើ ប៉ុល ពត ថាអាចច្បាំងឈ្នះ ។ ការពារបូរណភាពទឹកដីបាន ទទួលការពន្យល់នៅម៉ោងប្រាំបួន ថ្ងៃ០៦ មករា ពីបងហែម គឺ ខៀវ សំផន ទៀត ខ្ញុំកាន់តែជឿថា វាមិនអី ។ អ៊ីចឹង ខ្ញុំគិតតែដេកតទៅទៀត នេះទីមួយ ។ ទីពីរ មនុស្សដែលគេឲ្យខ្ញុំកម្ទេច កុំឲ្យនៅសល់នោះ គេឲ្យកម្ទេចតាំងពីថ្ងៃ០២ ឬក៏ថ្ងៃ០៣ យ៉ាងយូរ ខែមករា ១៩៧៩ ។ នៅសល់អ្នកទោសបួននាក់សម្រាប់សួរ ហើយនៅសល់អ្នកទោសប្រហែលជា-- ខ្ញុំចាំមិនអស់ទេ ព្រោះខ្ញុំមិនស្គាល់ ប្រហែលជាដប់បួន ឬ ដប់ប្រាំនាក់ សម្រាប់ប្រើ នេះសម្រាប់ប្រើ ។ ហើយនៅសល់តែម្នាក់ទេ គឺពួក *ហ្វុលរ៉ូ* ឈ្មោះ អ៊ី ប៉េញ អ៊ី បាញ ដែលរត់ទៅជាមួយនឹងខ្ញុំ នេះនៅសល់ប៉ុណ្ណឹង ខ្ញុំកម្ទេចធ្វើតាមគេទាំងអស់ នេះសូមបញ្ជាក់អ៊ីចឹង ។ ខ្ញុំគ្មានទឹកនាថា កម្ពុជាប្រជាធិបតេយ្យដួលរលំហើយ ចាញ់គេហើយ ត្រូវដោះលែងអ្នកទោសដើម្បីឲ្យវាសមនឹងឧត្ដមគតិខ្លួនដែលមិនពេញចិត្តនឹងការសម្លាប់មនុស្ស អត់បាននឹងនាវដល់រឿងហ្នឹងទេ ។ នេះសូមជម្រាបដោយត្រង់ប៉ុណ្ណេះ ។

**ស៖** សូមអរគុណនិងខ្ញុំសូមបន្តសំណួរមួយទៀត ។ ទាក់ទងទៅនឹងចំណុចមួយដែលលោកបានលើកឡើងថា លោកបានដឹងខ្លួនថាលោក-- នៅពេលដែលលោកបានដឹងថាគេចាប់លោក វន វ៉េត មកកាន់មន្ទីរស-២១ ។ ពេលនុំង លោកបានដឹងខ្លួន ខ្លួនលោកថាមនុស្សជំនិតរបស់បក្សកម្ពុជាប្រជាធិបតេយ្យ គឺត្រូវបានគេចាប់ទាំងអស់ ។ ហើយអ៊ីចឹងលោកក៏បានដឹងខ្លួនលោកដែរ ។ អ៊ីចឹង ពេលនុំង តើលោកមិនមានអារម្មណ៍ថា តើគួរតែរៀបចំខ្លួនយ៉ាងម៉េចដើម្បីជួយដល់អ្នកទោសនៅមន្ទីរស-២១ ដែរ ឬក៏យ៉ាងម៉េច? ព្រោះនេះគឺជាឱកាសមួយដែលលោកអាចរកមធ្យោបាយនៅក្នុងការជួយដល់អ្នកទោសមន្ទីរស-២១ ដែលយោងទៅតាមឧត្ដមគតិរបស់លោកដែលលោកតែងតែនិយាយថា ការសម្លាប់នុំងគឺ

លោកមិនពេញចិត្តទេ គឺគាត់ធ្វើដោយសារការបង្ខំ ។

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! បងវន ត្រូវចាប់នៅថ្ងៃ០២ វិច្ឆិកា ១៩៧៨ ដូច្នេះ តាំងពីចាប់បងវន មក ខ្ញុំធ្វើអីអត់កើតទេ ប៉ុន្តែគ្រាន់តែមិនដេកទាំងយប់ទាំងថ្ងៃ ។ ដល់ថ្ងៃមួយ ថ្ងៃ០២ ឬថ្ងៃ០៣ មករា គេឲ្យខ្ញុំបញ្ចេញអ្នកទោសនៅស-២១ ទាំងប៉ុន្មានឲ្យអស់ ។ ដំណឹងល្អិចល្អៀងអំពីរឿង ប៉ុល ពត រត់ផាសក្រញាំពីភ្នំពេញ គ្មាន ខ្ញុំអត់យល់ ។ គ្មាននរណាឲ្យខ្ញុំដឹង ហើយឮវិទ្យុគេអំពាវនាវក៏ខ្ញុំយល់មិនដល់ ដូច្នេះ ខ្ញុំអត់មានវិធានការអីទេ ក្រៅពីអស់សង្ឃឹមគិតតែពីដេក នេះសូមបញ្ជាក់ប៉ុណ្ណេះ ។

[០៩:៣៦:៥០]

**ស៖** ទាក់ទងទៅនឹងការអស់សង្ឃឹមរបស់លោក លោកតែងតែនិយាយថា លោកមានការអស់សង្ឃឹម គិតតែពីដេក ។ អ៊ីចឹង ខ្ញុំចង់សួរថា តើហេតុអ្វីបានជាលោកព្យាយាមអនុវត្តទៅតាមការបញ្ជារបស់ថ្នាក់លើតទៅទៀត?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា ។ ខ្ញុំអស់សង្ឃឹមនេះ វាមានដំណាក់ ពីអស់សង្ឃឹមតិច ទៅអស់សង្ឃឹមមែនទែន ធ្វើអីមិនកើត ដេក វាមានដំណាក់របស់វា ។ ចាប់ផ្តើមអស់សង្ឃឹមដំបូងនៅខែមករា ១៩៧៧ ដែលគេឲ្យចាប់កម្មាភិបាលភូមិភាគឧត្តរចូលមក នេះមួយកម្រិតហើយ ។ ដែលអស់សង្ឃឹមលើកទីពីរ កាន់តែធ្ងន់ទៅទៀត ដោយសារគេបញ្ជាឲ្យចាប់បង ង៉ែត យូ ហៅ ហុង បញ្ជូនមកឲ្យស-២១ បង ង៉ែត យូ ហៅ ហុងនេះជាអាណិកជនចិនដែលការពារបក្សកុម្មុយនីស្តកម្ពុជាតាំងពីណាពីណីមក ឥឡូវគេចាប់ប្រហែលជានៅខែមីនា ១៩៧៨ ។ អានេះ ខ្ញុំអត់បានមើលបញ្ជីនោះ ឡើងវិញទេ ។ ដូច្នេះ ខ្ញុំអស់សង្ឃឹមកាន់តែខ្លាំងហើយ ឈប់ធ្វើអីៗ ទៅអង្គុយសំកុកនៅកន្លែងគួរឆ្កាក់ ។ ដល់អស់សង្ឃឹមមួយកម្រិតទៀតនៅពេលថ្ងៃ០២ វិច្ឆិកា ១៩៧៨ ដែលគេចាប់ បងវន អស់សង្ឃឹមខ្លាំងមួយកម្រិតទៀត ។ ដល់ចុងបញ្ចប់ថ្ងៃ០២ ថ្ងៃ០៣ មករា ដែលគេបញ្ជាឲ្យបញ្ចេញអ្នកទោសឲ្យអស់ ខ្ញុំថាដល់ម៉ោងខ្ញុំហើយខ្ញុំ ខ្ញុំធ្វើអីអត់កើតទេ ដេកទាំងយប់ ដេកទាំងថ្ងៃ គិតតែពីដេក ។ ហ្នឹងវាទៅតាមកម្រិតអ៊ីចឹង ។ នៅពេលដែលយើងអស់សង្ឃឹមល្មមៗ យើងគិតថា អ្ហឺ! ថ្ងៃណាដល់វេនអញ ដូច្នោះ គិតធ្វើម៉េចឲ្យតែបានរស់កុំក្រវេចក្រវៀន គេឲ្យធ្វើយ៉ាងនេះ ត្រូវធ្វើយ៉ាងនេះឲ្យគេ កុំងាកស្តាំ កុំងាកឆ្វេង ។ នេះវិធានការវាស្របទៅតាមដំណាក់កាលនៃការអស់សង្ឃឹម ។ ដល់អស់សង្ឃឹមមែនទែន អត់បានគិតអីទេ ដេក ចប់ ។ សូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**កញ្ញា ទី ស្រ៊ីនណា៖**

សូមអរគុណ ។ ខ្ញុំអស់សំណួរត្រឹមប៉ុណ្ណឹងហើយលោកប្រធាន ។ ហើយនិងសូមបង្វែរសំណួរមួយចំនួនទៀតទៅមេធាវីអន្តរជាតិនៅក្នុងក្រុមរបស់នាងខ្ញុំ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី អាឡាំង វ៉ែនណឺ ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន ។ អរុណសួស្តី លោកជនជាប់ចោទ! មុនពេលដែលខ្ញុំចាប់ផ្តើមសំណួររបស់ខ្ញុំ ខ្ញុំសូមលើកពីរចំណុច ។ ទីមួយ ក្នុងនាមក្រុមរបស់ខ្ញុំ ខ្ញុំសូមលើកឡើងថា យើងទទួលស្គាល់នូវអ្វីដែលលោកបាន-- នៅរយៈពេលបួនថ្ងៃដែលលោកត្រូវបានចោទសួរ ។ ហើយលោកទទួលនូវសំណួរជាច្រើនហើយលោកពុះពារក្នុងការឆ្លើយសំណួរ ។ យើងសូមទទួលស្គាល់ចំពោះកិច្ចការប្រឹងប្រែងដូច្នេះ ។

[០៩:៤០:២៣]

ទីពីរ ដូចអ្វីដែលយើងបានកត់សម្គាល់កាលពីម្សិលមិញ យើងសូមអរគុណចំពោះភាពក្លាហានរបស់លោកនិងការឆ្លើយតបរបស់លោក ។ នេះអនុញ្ញាតឱ្យយើងសួរសំណួរជាច្រើនរបស់យើងក្នុងនាមកូនក្តីរបស់យើង សូមអរគុណជាមុន ។

**ស៖** សំណួរចំណុចទីមួយគឺទាក់ទងទៅនឹងករណី ទុយ លោកបានឆ្លើយតបសំណួររបស់ចៅក្រមថា ទុយ ជាអ្នកសួរចម្លើយនៅស-២១ ហើយ ទុយ ចូលចិត្តធ្វើទារុណកម្មណាស់ ។ នៅថ្ងៃអង្គារ៍ ថ្ងៃទី១៦ ខែមិថុនា លោកបានលើកឡើងដូចតទៅ នេះនៅក្នុងទំព័រ៤៥ នៃប្រតិចារឹក ។ ខ្ញុំសូមដកស្រង់។ ទុយ គឺមានការពេញចិត្តនឹងការងាររបស់គាត់ ហើយគឺគាត់ធ្វើការអនុវត្តការសួរចម្លើយ ទារុណកម្មក្តៅ។ ហើយលោកបានពន្យល់ក្នុងលក្ខណៈលម្អិតអំពីវិធានវិធីក្តៅនិងទារុណកម្មក្តៅ ។ ខ្ញុំចង់បញ្ជាក់ថា តើខ្ញុំយល់នេះត្រឹមត្រូវដែរឬទេ? តើវាត្រឹមត្រូវថា ទុយ ដែលរីករាយក្នុងការធ្វើទារុណកម្មក្នុងគំនិតផ្តួចផ្តើមរបស់គាត់ គឺបុគ្គលនេះគាត់ជាអ្នកបង្កើតរបៀបធ្វើទារុណកម្មក្តៅ ។ តើមែនដែរឬទេ? តើវាត្រឹមត្រូវដែរឬទេ? លោកទទួលស្គាល់ទៅលើចំណុចនេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! បញ្ហានេះយើងមិនត្រូវទម្លាក់កំហុសទៅលើកូនចៅ ដែលជាអ្នកអនុវត្តទេ ទាំងស្រុងទេ ។ របៀបធ្វើទារុណកម្មក្តៅ ខ្ញុំក៏បាននិយាយជាមួយនឹងគេដែរ ដែលហៅ

ថា ទារុណកម្មក្តៅគឺត្រូវប្រើទារុណកម្មជាបន្តបន្ទាប់ នេះជាការណែនាំរបស់ខ្ញុំ ។ ក៏ប៉ុន្តែ អត្តចរិតរបស់អ្នកសួរទាំងអស់នៅស-២១ មិនដូចគ្នាទេ ។ មិត្តទុយ មកពីខាង៧០៣ មានសសៃញ្ញាក់មួយរត់ទៅរកទារុណកម្មក្តៅ មិត្តណាន, ប្រាក់ ណាន មកពី ម-១៣ ក៏មាននិស្ស័យមួយជាសសៃញ្ញាក់រត់ទៅរកទារុណកម្មក្តៅដែរ គិតគូឲ្យតម្លៃទៅលើទារុណកម្មក្តៅជាធំ ។ ឯចំណែក មិត្តប៉ុន គេជាកម្មាភិបាលសួរចម្លើយដែលខ្ញុំបណ្តុះបណ្តាលដោយផ្ទាល់ហើយមានពិសោធន៍ជាងគេ គេមិនងាយធ្វើស្អីដែលលើសអំពីសំណួមពរនៃការងារជាក់ស្តែងទេ ។ ដោយឡែក មានអ្នកខ្លះចេះគិតចេះគូរវែងឆ្ងាយដូច ឧទាហរណ៍ បង ម៉ម ណៃ អ៊ីចឹងមិនធ្វើទារុណកម្ម សឹងតែថាមិនធ្វើក៏បានដែរ ប៉ុន្តែធ្វើក៏តិចបំផុត នៅពេលដែលគាត់ទាល់ច្រក ។

[០៩:៤៤:០៥]

ដូច្នេះសរុបមក ទារុណកម្មក្តៅ ដោយប្រើទារុណកម្មយើងខ្ញុំបានអនុញ្ញាតជាគោលការណ៍ តាមគោលការណ៍បក្សកំណត់ ។ និស្ស័យរបស់មនុស្សវាខុសគ្នា ទុយ ហើយនិង ណាន ទៅផ្សេង មិត្ត ប៉ុន ទៅផ្សេង បង ម៉ម ណៃ ទៅផ្សេង ។ ដូច្នេះ ខ្ញុំអត់បន្ទោសកូនចៅទាំងស្រុងទេ មាគ៌ាដែលខ្ញុំណែនាំគេវាមាន ។ នេះសូមបញ្ជាក់ជូនលោកមេធាវីប៉ុណ្ណោះ ។

**ស៖** ត្រឡប់ទៅដល់ករណី ទុយ ហេតុអ្វីបានជាលោកអនុញ្ញាតឲ្យ ទុយ ទៅលើអំណាចនៅ ស-២១ នៅពេលដែលលោកដឹងអំពីសរសៃញ្ញាក់ដែលថា គាត់ជាអ្នកចូលធ្វើដូច្នេះហើយ ។ ហេតុអ្វីលោកផ្តល់ការងារហ្នឹងទៅដល់គាត់?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! គេមិនមានកំហុសអីល្មមនឹងដកគេបាននោះ យើងខ្ញុំមិនដកទេ នេះទីមួយ ។ ទីពីរ អ្នកណាដែល-- អ្នកផ្សេងទៀតសួរចម្លើយមិនចេញយើងខ្ញុំរុញទៅឲ្យទុយ ។ ទុយសួរចម្លើយចេញ ។ ខុសមហាខុសហើយ ប៉ុន្តែវាចេញ ។ ដើម្បីជាចម្លើយប្រាប់ថា នេះវាបានឆ្លើយដើម្បីខ្ញុំប្រាប់ទៅខាងលើ ។ ខុសនោះពិតជាខុស ។ ដូចខ្ញុំបាន (សូមទោស) ខ្ញុំសូមអនុញ្ញាតលើកឧទាហរណ៍ចម្លើយមួយចុះ ចម្លើយបង សៀត ឆែ ហៅ ទុំ ។ និយាយចុះនិយាយឡើង ទុយ សួរចុះសួរឡើងទៅជាបង សៀត ឆែ ហៅ ទុំ សារភាពថាគាត់ខូចជាមួយនឹងកូនស្រីរបស់គាត់ ។ វាជារឿងហួសហេតុ ។ ក៏ប៉ុន្តែ វាស្ថិតនៅក្នុងក្របខ័ណ្ឌដែលយើងគ្រាន់តែព្រមានទេ បើសិនជាគេវាយស្លាប់កណ្តាលការណ៍ អាហ្នឹងវាមានផ្លូវ បើសិនជាវាយស្លាប់កណ្តាលការណ៍ ដោយមានគំនុំសងសឹកអាហ្នឹងយើងមានសិទ្ធិវាយការណ៍ទៅលើសុំចាប់ ។ ដូច្នេះ ទុយ នៅជាមនុស្សមានប្រយោជន៍សម្រាប់ការងារសួរ

ចម្លើយ ទុយមានបង្អែកមួយធំគឺកម្លាំងរបស់កងពល៧០៣ យើងប៉ះពាល់ផ្ដេសផ្ដាសមិនបានទេ គេគឺជាកម្លាំងធំនៅក្នុងអង្គភាពនេះ ។ ដូច្នេះ គោលការណ៍ បើសិនជាគេវាយស្លាប់ដាច់ចម្លើយដោយសារកំហឹង ដោយសារគំនុំសងសឹក យើងមានលេសចាប់គេបាន ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** នៅថ្ងៃអង្គារ៍ ថ្ងៃ១៦ ខែមិថុនា នៅក្នុងទំព័រ៦១ និង ៦២ នៅក្នុងប្រតិចារឹក លោកបានជម្រាបអង្គសវនាការថា "អ្នកសួរចម្លើយក្មេងៗគឺមានលក្ខណៈសាហាវនិងដាច់ណាត់ ហើយពួកគាត់មានម្ចាស់ការលើខ្លួនឯង ហើយពួកគេមានភាពសាហាវណាស់" ។ តើលោកទទួលស្គាល់ទៅលើការផ្ដល់លក្ខណៈបែបនេះដែរឬទេចំពោះ ទុយ ផងដែរ ដែលថា លោកជំរុញអ្នកសួរចម្លើយក្មេងៗឲ្យធ្វើការធ្វើបង្កើតការឈឺចាប់ទៅលើភាពដែលវាហួសពីអ្វីដែលចង់បាន?

[០៩:៤៨:០៤]

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ឲ្យយើងខ្ញុំជំរុញគេតទៅទៀត មិនជំរុញទេ ។ ក៏ប៉ុន្តែការដែលយើងខ្ញុំចេះតែនៅទុកចិត្តគេប្រើគេតទៅទៀត ណែនាំគេជាពាក្យសម្ដីតិច ឬច្រើន វាមានឥទ្ធិពលឲ្យគេនៅតែស្នេហ៍ស្និតនឹងអាទារុញកម្មធ្ងន់ហ្នឹងតទៅទៀតមែន ។ នេះគឺសូមៗបញ្ជាក់អ៊ីចឹងមែន ។ ហើយសូមបញ្ជាក់ឡើងវិញ មនុស្សដែលខ្ញុំភ្លាប់បានថាមានសរសៃញាក់ទៅខាងទារុណកម្មមានពីរ ។ ទីមួយគឺ មិត្តទុយ មកពីកងពល៧០៣ ទីពីរ មិត្តណាន មកពីម-១៣ ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណឹង ។

**ស៖** ខ្ញុំចង់សួរសំណួរអំពីភាពអត់ឃ្លាននិងការដាច់ពោះស្លាប់ ។ លោកត្រូវបានចោទសួរលើបញ្ហានេះច្រើន ។ លោកបានបញ្ជាក់នៅថ្ងៃច័ន្ទកាលពីអាទិត្យមុននៅថ្ងៃច័ន្ទ ថ្ងៃទី១៥ នៅទំព័រទី៩៨ លោកនិយាយថា មនុស្សស្លាប់ដោយសារអត់អាហារនៅស-២១ ដោយសារតែគាត់មិនមានអ្វីហូបចុក ហើយលោកបាននិយាយដូចនេះផងដែរ គឺនៅក្នុងប្រតិចារឹកនៅក្នុងទំព័រ៨៩ ថ្ងៃទី១៥ លោកនិយាយថា និយាយជាទូទៅ គឺមិនមានអាហារគ្រប់គ្រាន់ហូបនៅក្នុងទូទាំងប្រទេសចំពោះប្រជាជន ហើយអ្នកទោសក៏ដូចគ្នាដែរ ។ ហើយនេះជាគោលនយោបាយទូទៅ របស់បក្សកុម្មុយនីស្តកម្ពុជា ហើយចៅក្រមសួរលោកថា តើលោកដឹងអំពីការអនុវត្តចំពោះគោលនយោបាយនោះដែរឬទេ? លោកបានឆ្លើយថាលោកដឹង ហើយលោកថា មានអារម្មណ៍ឈឺចាប់ចងចាំចំពោះលោក ហើយលោកអត់អាចធ្វើអ្វីបាននិងលោកគ្មានជម្រើសនោះទេ ។

ដូច្នេះ នៅក្នុងនេះគឺមានឧទាហរណ៍មួយដែលបង្ហាញថាលោកអាចជម្រើស ។ លោកបានបញ្ជាក់ថា នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៨ គឺឯកសារលេខ D63 គឺលេខ 00178037 ដែលលោក

បានបង្ហាញជូនចៅក្រមស៊ើបអង្កេត ។ លោកបានត្រូវបានសួរថា-- លោកត្រូវបានចៅក្រមស៊ើបអង្កេតសួរថា លោកបានពន្យល់ថានៅក្នុងឆ្នាំ១៩៧៨ ភាពលើសលប់ដែលនៅសល់ពីស្រូវ គឺវាលើសពីហាសិបភាគរយ ។ ហើយតើហេតុអ្វីបានជាលោកដឹងអំពីមានស្រូវលើសនេះ? ហើយហេតុអ្វីបានជាលោកដឹងថា ស្រូវនោះឲ្យទៅមជ្ឈិម ជាជាងការប្រើប្រាស់នៅក្នុងការផ្តល់អាហារទូទៅទៅដល់បុគ្គលិក? លោកបានឆ្លើយថា "លោកអត់ចាំ" ប៉ុល ឬក៏ ហ៊ុយ ដែលគាត់ប្រាប់ខ្ញុំ ហើយនៅក្នុងឆ្នាំនោះមានស្រូវលើសហើយយើងមានស្រូវ ។ ហើយខ្ញុំចង់ជួយអង្គភាពផ្សេងៗ ។ ខ្ញុំចង់លើកតម្កើងកេរ្តិ៍ឈ្មោះស-២១ និងស-២៤ ព្រៃសផងដែរ ទាក់ទងទៅនឹងរបបអាហារ ។ ហើយចំពោះរបបអាហារ គឺមេជាអ្នកកំណត់ខ្ញុំអត់អាចកែប្រែទៅលើការកំណត់នោះទេ ។ សំណួររបស់ខ្ញុំនៅពេលនេះគឺថា ហេតុអ្វីបានជាលោកផ្តល់ស្រូវលើសនោះទៅដល់ នួន ជា នៅពេលដែលលោកដឹងថា អ្នកទោសនៅស-២១ គឺគាត់កំពុងតែស្លាប់ដោយសារខ្វះអាហារហើយនោះ?

[០៩:៥២:២៣]

**ឌុះ** ជម្រាបប្រសាសន៍លោកមេធាវី! រឿងដែលខ្ញុំបានជម្រាបលោកចៅក្រមស៊ើបអង្កេត អត់ខុសទេ ។ ឆ្នាំ១៩៧៨ នេះ ស-២១ មជ្ឈមណ្ឌលព្រៃសបង្កបង្កើនផលបានស្រូវលើសចំនួន លើសសេចក្តីត្រូវការចាំបាច់ប្រចាំឆ្នាំរបស់ខ្លួនច្រើនតោនដែរ ។ ខ្ញុំមិនចាំប៉ុន្មានតោនទេ ច្រើនឆ្នាំហើយ ។ ហើយខ្ញុំពិតជាបានជូនស្រូវនេះទៅអង្គការតាមរយៈ ពូនួន ។ ពូនួន ឲ្យគេមកដឹក ។ នេះជារឿងពិត ។

ក៏ប៉ុន្តែរឿងដែលយើងចង់និយាយនៅពេលនេះ គឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ វាទៅទាំងគេ វាទៅទាំងខ្ញុំ ជាពិសេសខ្ញុំ ។ ដែលមានស្រូវនៅក្នុងដៃហើយអត់ប៉ានដោះស្រាយឲ្យអ្នកទោសនៅក្នុងគុកនៅភ្នំពេញ យើងហៅគុកទៅចុះ ។ តាមពិតមិនមែនគុកទេ ជាកន្លែងស្តុកមនុស្សសម្រាប់យកទៅវាយចោល ។ អត់ប៉ានដោះស្រាយរបបឲ្យលើសជូនអ្នកដែលត្រូវអប់រំសាថ្មីនៅមជ្ឈមណ្ឌលព្រៃស នៃស-២១ ដែលយើងហៅថាស-២៤ នោះទេ ។ ហើយក៏មិនប៉ានកែប្រែរបបដែលបក្សកំណត់សម្រាប់យុទ្ធជននិងកម្មាភិបាល ស-២១ ទាំងមូលដែរ ។ នេះវាជាបទឧក្រិដ្ឋដែលវាទៅទាំងគេ ទៅទាំងខ្ញុំជាពិសេសខ្ញុំក្នុងឋានៈជាអ្នកកាន់កាប់កិច្ចការនៅ ស-២១ មិនប៉ានតវ៉ា មិនប៉ានទាមទារ ឬក៏មិនប៉ានលួចគោលការណ៍ចាត់តាំងខាងម្ហូបអាហារនេះ ខាងរបបម្ហូបអាហារនេះ វាជាឧក្រិដ្ឋកម្មដែលខ្ញុំត្រូវទទួលដោយខានមិនបានឡើយ ។ នេះវាជាស្មារតី នេះវាជាស្មារតីប្រឆាំងមនុស្សជាតិដែលយើងខ្ញុំកំពុងតែទទួលរងការវិនិច្ឆ័យទោសរបស់តុលាការ ។ សូមទទួល ។

**ស៖** កាលពីអាទិត្យមុន ឆ្លើយតបទៅនឹងលោកចៅក្រមម្នាក់ លោកបានពន្យល់ដោយពិស្តារ ។ គឺមានការឆ្លើយតបរវាងលោក និង លោកចៅក្រម ឡាវ៉ែន៍ គឺនៅទំព័រទី៨១ នៃប្រតិចារឹក នៃថ្ងៃ១៥ លោកថា លោកមានជម្រើសក្នុងការមិនទាក់ទងជាមួយនឹងអ្នកទោស ។ នៅពេលដែលលោកជួបពួកគេ ឃើញពួកគេ លោក១មានអារម្មណ៍ឈឺចាប់ណាស់ ហើយលោកបាននិយាយថ្ងៃក្រោយមកទៀត លោកមានការភ័យខ្លាចក្នុងការឃើញភាពឈឺចាប់របស់អ្នកទាំងអស់នោះ លោកបិទត្រចៀក បិទភ្នែករបស់លោក ប៉ុន្តែលោកមិនចង់ឃើញស្ថានភាពបែបនោះទេ ហើយគឺលោកមិនចង់ឃើញ ឃើញទៅលើស្ថានភាពនោះទេ ។

*(អ្នកបកប្រែ៖ សុំអនុញ្ញាតឲ្យលោក វ៉ែនណឺ និយាយឲ្យបានយឺតដើម្បីធ្វើការកត់ត្រាក្នុងប្រតិចារឹក)*

ដូច្នេះលោកមិនចូលទៅដល់គុកនោះទេ ដែលអ្នកទាំងអស់នោះ គាត់ស្លាប់ដោយសារភាពអត់ឃ្លាន ។ តើត្រឹមត្រូវដែរ ឬទេ?

[០៩:៥៦:១៦]

**ប្រធានអង្គជំនុំ៖**

និយាយឲ្យបានយឺតជាងហ្នឹងបន្តិច ព្រោះមានការបកប្រែមិនទាន់ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអភ័យទោសលោកប្រធានចំពោះករណីនេះ ។ ខ្ញុំគួរតែបន្តនូវអ្វីដែលខ្ញុំចង់សួរទៅទៀត ។ ខ្ញុំសូមសង្ខេប មូលហេតុហេតុអ្វីបានជាលោកមិនចូលទៅគុកនោះ? ហើយលោកបានពន្យល់ថាទីកន្លែងនោះគឺជា កន្លែងដែលមនុស្សស្លាប់ដោយសារតែជំងឺ ការភ័យខ្លាច ការអត់អាហារ និងការធ្វើទារុណកម្ម ។ ហើយលោកមិនចូលទៅទីនោះដោយសារតែវាប៉ះពាល់អារម្មណ៍របស់លោក ។

ដូច្នេះ យើងជឿថាសេចក្តីពិតវាមាននៅកន្លែងផ្សេង ហើយខ្ញុំពន្យល់ទៅលើលោក ហើយខ្ញុំដាក់ចំណុចនេះឲ្យលោកពិចារណា ។

**ស៖** ហើយបន្ទាប់ពីចំណុចនេះ ខ្ញុំនឹងសួរសំណួរទៅកាន់លោក ។ ខ្ញុំធ្វើឡើងគឺក្នុងនាមអ្នករងគ្រោះ លោកជឿថា នៅពេលដែលលោកជាប្រធានស-២១ អ្វីដែលលោកធ្វើនោះគឺដើម្បីបំពេញចិត្តថ្នាក់លើរបស់លោកគឺ សុន សេន បន្ទាប់មក នួន ជា ។ លោកទៅរោងឆ្លាក់ ដោយសារតែលោកចង់គេចចេញនិងចង់យកចិត្ត ប៉ុល ពត ។ ហើយលោកធ្វើការយកចម្លើយវៀតណាម ដោយសារតែលោកចង់ធ្វើការផ្សព្វផ្សាយ ហើយធ្វើដូច្នេះដើម្បីសម្រួលទៅដល់ដំណើរប្រតិបត្តិការ ។ ហើយលោកធ្វើការវិភាគនិង

អានចម្លើយសារភាពទាំងអស់នោះគឺដើម្បីយកចិត្តមេរបស់លោក ។ ហើយលោកនិយាយថា លោកមិនចូលទៅដល់គុក ដោយសារតែចូលទៅគុកនោះ គឺគ្មានអ្វីប្រយោជន៍សម្រាប់លោកនោះទេ ។ ហើយការឈឺចាប់របស់អ្នកទោស គឺគ្មានពាក់ព័ន្ធនឹងលោក ហើយវាមិនជាប់ទាក់ទងទៅនឹងអ្វីដែលលោកថា លោកមានបំណងយកចិត្តមេរបស់លោក ។

យើងជឿថា ការឈឺចាប់ទាំងអស់នោះគឺគ្មានតម្លៃសម្រាប់លោក ។ ហើយ ដូច្នេះហើយគឺលោកបានលើកឡើងថា វាប៉ះពាល់អារម្មណ៍ចំពោះរូបលោក ។ តើលោកនិយាយយ៉ាងម៉េច ចំពោះបញ្ហាទាំងអស់នេះ?

**ឌ៖** ជម្រាបប្រសាសន៍លោកមេធាវី! សេចក្តីសន្និដ្ឋានរបស់លោក ចំពោះរូបខ្ញុំ ចំពោះសតិអារម្មណ៍ខ្ញុំ ត្រឹមត្រូវជាមូលដ្ឋាន ។ ត្រឹមត្រូវគឺ ខ្ញុំខំយកចិត្តមេមែន ។ ទៅកន្លែងគួរឆ្កាក់ក៏ដើម្បីជំរុញឲ្យគេធ្វើឲ្យបានល្អដើម្បីយកចិត្តមេ ។ អានឯកសារ ខំចារឯកសារ ក៏ដើម្បីយកចិត្តមេ ធ្វើម៉េចបង្ហាញការងារហ្មត់ចត់របស់ខ្លួនទៅឲ្យមេដឹង ។ សរុបមក នេះវាជាទិដ្ឋភាពមួយដែលយើងខ្ញុំយល់ថា ខំប្រឹងខ្នះខ្នែងឲ្យអស់ពីចិត្តថ្លើម ទៅតាមការដែលខាងលើចង់បាន ។ បើតាមខ្ញុំយល់ ហ្នឹងហើយដែលបារាំងហៅថា *"ហ្សែល"* ហ្នឹង ។ នេះម្យ៉ាងហើយត្រឹមត្រូវខ្ញុំទទួលស្គាល់នូវឧក្រិដ្ឋកម្មរបស់ខ្ញុំដែលខ្ញុំបានចូលរួមក្នុងឋានៈជា ប្រធានមន្ទីរស-២១ ពោរពេញទៅដោយគំនិតខ្នះខ្នែង ។

ក៏ប៉ុន្តែ ខ្ញុំសូមគ្រាន់តែជម្រាបបញ្ជាក់ថា ខ្ញុំមិនបានទៅអើតមិត្តភក្តិដែលចូលមកជាប់នៅនោះមនុស្សច្រើនណាស់ដែលចូលមក ស-២១ ខ្ញុំស្គាល់តែខ្ញុំ អត់ប៉ានទៅអើត នេះជារឿងពិត ។ ម្សិលមិញលោក គឹមសួន បង្ហាញខ្ញុំឈ្មោះ ជា ខន ហ្នឹងជាមិត្តភក្តិ គាត់អត់បានចូលបក្សទេ បើតាមខ្ញុំស្មាន។ ហើយមួយទៀត ឈ្មោះ ជីង ឈុនឡាំង ក៏ជាមិត្តភក្តិដែល ប្រហែលជាអត់បានចូលបក្សដែរ ។ មួយទៀតឈ្មោះ ទៀន ទីនី ក៏អត់បានចូលបក្សដែរ។ ខ្ញុំដឹងថាពួក នេះមកដល់ ស-២១ តែខ្ញុំអត់ប៉ានទៅជិតទេ ។ ទៅជិតមិនដឹងជាយកពាក្យអីទៅនិយាយជាមួយគេ ។ ឯចំណែកមិត្តភក្តិដែលចូលបក្សក៏ច្រើនដែរ ដូចជាមិត្ត ម៉ប ឈឿយ ហៅ ឌុច ដូចជាបង ឆាយ គឹមហ៊ី ហ្នឹងអ្នកអប់រំខ្ញុំទៅទៀត ខ្ញុំអត់ប៉ានទៅជិត មិនដឹងជាយកពាក្យអីទៅនិយាយជាមួយនឹងគេទេ ។ ដូច្នេះ នេះតាមសេចក្តីសន្និដ្ឋានជាហូរហែមក ជាពិសេសចុងក្រោយនេះលោកចៅក្រម វ៉ែនណឺ លោកថាអ្នកឯង កំសាកតើអ្នកឯងទទួលស្គាល់បាតុភាពនេះទេ? ខ្ញុំថាខ្ញុំទទួលស្គាល់ ក៏ប៉ុន្តែលើសពីកំសាកទៅទៀតមិន ដឹងជាយកពាក្យស្អីទៅដាក់ទេ ។ ខ្ញុំជម្រាបលោកចៅក្រមវ៉ែនថា ត្រូវហៅថាសតិអារម្មណ៍ក្បត់ ក្បត់មិត្ត ក្បត់ភក្តិ ក្បត់គ្រូបា

អាចារ្យ ដើម្បីតែខ្លួនឯងរស់ប៉ុណ្ណោះ ។ នេះខ្ញុំសូមទទួលស្គាល់បញ្ហានេះ ចំពោះមុខអង្គជំនុំជម្រះនេះទទួលឧក្រិដ្ឋកម្មនេះដោយចំមុខ ។ នេះសូមជាតិប្រជាជនលោកមើលមកខ្ញុំឲ្យឃើញ ច្បាស់ថាឧក្រិដ្ឋកម្មរបស់ខ្ញុំជំនាន់នុំងអ៊ីចឹងមែន ។ នេះសូមបញ្ជាក់អ៊ីចឹង។

**សៈ** យើងជឿជាក់ថាតាមពិតទៅគឺលោកបានជោគជ័យនៅក្នុងការបំពេញបំណងធ្វើឲ្យមេរបស់លោកសប្បាយចិត្ត។ ខ្ញុំចង់លើកនូវចំណុចមួយថា ចំណុចមួយដែលលោក ដុកទ័រ អេតធេសាន់ បានមកផ្តល់សក្ខីកម្មនោះហើយគាត់បានពន្យល់ថា ហេតុផលមួយក្នុងចំណោមហេតុផលផ្សេងៗដែលគាត់បានពន្យល់ ហេតុអ្វីបានជាលោកត្រូវបានគេចាត់តាំងឲ្យទៅជាប្រធានស-២១ ហើយជំនួសឲ្យ ណាត វិញ ដែលលោកបាននិយាយកាលពីថ្ងៃទី២៨ ខែ៥ នៅលើទំព័រ២០ នៃប្រតិចារឹក ។ ពេលនោះ គឺខ្ញុំបានសួរសំណួរដោយខ្លួនខ្ញុំផ្ទាល់ ហើយខ្ញុំនិយាយអំពីបញ្ជីឈ្មោះខ្មាំង ហើយពេលនោះគាត់បាននិយាយថា បាទខ្ញុំនឹងដកស្រង់ឃ្លាដែលគាត់ត្រូវបាននិយាយនៅក្នុងប្រតិចារឹក ។ តាមអ្វីដែលខ្ញុំយល់គឺថា នោះគឺជាការអនុវត្តដែលត្រូវបានធ្វើឡើងនិងកែច្នៃដោយជនជាប់ចោទខ្លួនឯងផ្ទាល់ ហើយជនជាប់ចោទនិងមេរបស់គាត់ជឿថា ការអនុវត្តបែបហ្នឹងគឺមានអត្ថប្រយោជន៍ខ្លាំងណាស់ ។ នេះហើយជាហេតុផលដែលបណ្តាលឲ្យជនជាប់ចោទត្រូវបានទទួលតំណែងជាប្រធាន ស-២១ បិទការដកស្រង់មកវិញ ។ ដូច្នេះ សំណួររបស់ខ្ញុំគឺថា នៅពេលដែលលោកត្រូវបានតែងតាំងជាប្រធានស-២១ គឺមកពីលោកបានបំពេញបំណងតាមមេរបស់លោកដោយបានត្រឹមត្រូវ ហើយមេរបស់លោកហ្នឹងឯងគឺបានទទួលបញ្ជីឈ្មោះ ខ្មាំងដែលលោកបានផ្តល់ឲ្យនោះ តើត្រឹមត្រូវដែរឬទេ?

[១០:០៥:០០]

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! សេចក្តីសន្និដ្ឋានរបស់ អាឡាំង វ៉ែនណឺ ខ្ញុំសូមអនុញ្ញាតទុកមួយឡែក ។ ខ្ញុំសូមនិយាយអំពីការដែលខ្ញុំខំធ្វើដើម្បីផ្គាប់ផ្គន់មេ ។ នៅពេលនេះគឺខ្ញុំសូមនិយាយបញ្ហានេះ។ ខ្ញុំពិតជាបានខំធ្វើការទាំងយប់ទាំងថ្ងៃគ្មានខ្លាចនឿយ គ្មានខ្លាចហត់ទេ ធ្វើម៉េចឲ្យតែបានមេពេញចិត្ត នេះជារឿងមួយ ។ មេប្រើទាំងយប់ខំទាំងយប់ មេប្រើទាំងថ្ងៃខំទាំងថ្ងៃ ។ ហើយខ្ញុំសូមបញ្ជាក់ថា ពាក្យដែលមានចែងនៅក្នុងមាគ៌ាបក្សអំពីស្មារតីច្នៃប្រឌិត សូមកុំភ្លេចថា គ្មានអ្នកណាហ៊ានច្នៃប្រឌិតឲ្យខុសមាគ៌ាបក្សទេ ។ អ្នកឯងហ៊ានច្នៃប្រឌិតឲ្យខុសមាគ៌ាបក្សអ្នកឯងក្បត់ ត្រូវចាប់ ។ នេះជាការចាំបាច់ ។ ច្នៃប្រឌិតនៅមន្ទីរស-២១ មានសភាពការណ៍តម្រូវ ខ្ញុំត្រូវពុះពារហៅយុទ្ធជននិងកម្មាភិបាលសួរ (សុំទោស) ហៅកម្មាភិបាលសួរចម្លើយមកអប់រំ តាមពាក្យដែលខ្ញុំថា “វ៉ៃរហ័សឈ្នះរហ័ស”

នេះដែលហៅថាច្នៃប្រឌិតក្នុងក្របខ័ណ្ឌនៃមាគ៌ាបក្ស ។ មែន ខ្ញុំបានធ្វើអ៊ីចឹងមែន ។ នេះជារឿងពិត ។ សមត្ថភាពខ្ញុំច្នៃប្រឌិតប៉ុណ្ណឹង គោលការណ៍បក្សអនុគ្រោះឲ្យខ្ញុំច្នៃប្រឌិតក្នុងក្របខ័ណ្ឌមាគ៌ាអ៊ីចឹង ។ នេះវាជារឿងពិត ។ នេះខ្ញុំសូមបញ្ជាក់អំពីការដែលខ្ញុំខំធ្វើការខ្នះខ្នែងធ្វើឲ្យគេពេញចិត្ត ។ នេះខ្ញុំសូមបញ្ជាក់អ៊ីចឹង ។ ហើយខ្ញុំសុំទោសណ៎ា ភ្លេចសំណួរលោកពាក់កណ្តាលហើយ ខ្វះត្រង់ណាសូមសួរមកទៀតចុះ ។

**ស៖** លោកបានពន្យល់នៅចំពោះមុខអង្គសវនាការជាច្រើនដងថា មនុស្សដែលសំខាន់ក៏ដោយក៏ត្រូវបានគេចាប់ខ្លួន ហើយនិងដាក់ឃុំឃាំងនៅស-២១ ទៅតាមចម្លើយសារភាពដែលត្រូវបានពាក់ព័ន្ធនោះ ។ ហើយលោកក៏បាននិយាយថា គឺមានចម្លើយសារភាពសំខាន់ពីរដែលលោកបាននិយាយប្រាប់ដល់សហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី១ ខែ៤ ឆ្នាំ២០០៨ គឺឯកសារ D67 នៅទំព័រទី៤ និងទី៥ ។ លោកបាននិយាយថា មនុស្សពីរនាក់គឺបានឆ្លើយដាក់ខ្ញុំនៅក្នុងចម្លើយសារភាពរបស់គាត់គឺ កែ គឹមហួត ហើយនិង វន វ៉េត ។ ហើយនៅពេលនីមួយៗ ខ្ញុំនៅតែរក្សាចម្លើយសារភាពនោះដដែល បើសិនជាខ្ញុំធ្វើអន្តរាគមន៍នោះគឺខ្ញុំនឹងបាត់បង់ការទុកចិត្តរបស់ខ្ញុំហើយ ។ កែ គឹមហួត បាននិយាយថា ខ្ញុំចាប់អារម្មណ៍តែទៅលើកម្ពុជាប្រជាធិបតេយ្យ ហើយនិងឧត្តមភាពតែប៉ុណ្ណោះ ។ ហើយខ្ញុំគឺជាសិស្សរបស់គាត់នៅសាលាបឋមសិក្សានៅឆ្នាំ៥៦ និង៥៧ ហើយគាត់បានឲ្យសៀវភៅពីរមកខ្ញុំ ដែលសៀវភៅនោះ គឺវាមិនស៊ីគ្នាទៅនឹងមាគ៌ានយោបាយរបស់បក្សទេ ។ សំណួររបស់ខ្ញុំគឺដូចខាងក្រោមនេះ ហេតុអ្វីបានជាមិនមានរឿងអ្វីកើតឡើងចំពោះលោក ទោះបីជាលោកត្រូវបានគេឆ្លើយដាក់ចំនួនពីរដង នៅក្នុងចម្លើយសារ-ភាពដូចដែលលោកបាននិយាយដូច្នេះអ៊ីចឹង ហើយអ្នកដែលឆ្លើយដាក់នោះគឺជាមនុស្សសំខាន់ៗទៀត ។ តើនេះមកពី សុន សេន ហើយនិង នួន ជា ការពារលោកឬ? មកពីលោកខិតខំប្រឹងប្រែងធ្វើការដើម្បីពួកគេនោះ?

[១០:០៨:១៨]

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ចម្លើយបង គឹមហួត មកលើខ្ញុំជាសកម្មភាពចាស់តាំងពីឆ្នាំ៥៦-៥៧ ម្ល៉ោះ ។ ដូច្នេះ ខាងលើគេអត់រាប់ទុកជាបានការទេ ។ ឯចម្លើយ បងវន មកលើខ្ញុំ អ្នកណាក៏គេដឹងថាបង វន ធ្លាប់គ្រប់គ្រងខ្ញុំ ខ្ញុំធ្លាប់គោរពកោតខ្លាចគាត់ ។ ខ្ញុំមានមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅទៅលើគាត់ អ្នកណាក៏គេដឹង ។ រួចចម្លើយគាត់មកលើខ្ញុំមិនដឹងយ៉ាងម៉េចទេ? ក៏ប៉ុន្តែ ដែលខ្ញុំចាំច្បាស់គឺគាត់សរសេរឈ្មោះខ្ញុំនៅចុងទំព័រខាងពេលសរុបហ្នឹង ខ្ញុំអត់កែ ទុកទៅជូនពូនួន ឲ្យពូ នួន

វិនិច្ឆ័យទៅ ឲ្យវាច្បាស់។ បើខ្ញុំលូកដៃកែ អ្នកផ្សេងទៀតគេឃើញ អូ អាឌុច ហ្នឹងវាទៅកែលុបឈ្មោះវាកុំឲ្យជាប់ឈ្មោះ ចុះកូនចៅខ្ញុំគេវិនិច្ឆ័យខ្ញុំយ៉ាងម៉េច? ឥឡូវដាក់ បើថាវាជាប់គុកងាប់ក៏ងាប់ទៅ ព្រោះអ្នកផ្សេងទៀតយើងអត់កែ បើកាលណាចំឈ្មោះយើង យើងទៅកែម៉េចបាន? ដូច្នេះ ត្រូវប៉ាន់ប្រឈមនឹងសភាពការណ៍ហ្នឹង ងាប់ៗទៅធ្វើម៉េច? ក៏ប៉ុន្តែរឿងដែលខ្ញុំមិនស្តាប់ ខ្ញុំនៅតែទទូចនិយាយថា ខ្ញុំត្រង់នឹងគេ ។ ប្រសិនបើសួរខ្ញុំថា ម៉េចបានជាខាងលើចាប់ ណាត មិនចាប់ខ្ញុំ? ខ្ញុំមានព្រឹត្តិការណ៍ជាប្រវត្តិ-សាស្ត្ររាយការណ៍ជូន ។ បើសិនលោកមេធាវីត្រូវការខ្ញុំនឹងរាយការណ៍ជូន ។

**ស៖** លោកបានឆ្លើយសំណួររបស់ខ្ញុំហើយ សូមអរគុណ។ ឥឡូវនេះខ្ញុំចង់លើកអំពីប្រធានបទពីរទៀត។ ទីមួយ ទាក់ទងទៅនឹងអ្វីដែលលោកបាននិយាយកាលពីសប្តាហ៍មុន នៅក្នុងអង្គសវនាការលោកបាននិយាយជាច្រើនដងថា លោកបានសហការជាមួយនឹង សុន សេន កាលពីថ្ងៃទី១៥ ខែមិថុនាគឺនៅទំព័រទី២៦ លោកបានពន្យល់ថាអ្វីទាំងអស់ដែលលោកធ្វើគឺដើម្បីជាកិច្ចសហប្រតិបត្តិការដល់លោក សុន សេន ។ ហើយគឺថាគាត់ចង់បានមតិពីលោកជាញឹកញាប់។ ហើយនៅថ្ងៃទី១៦ ខែមិថុនា នៅទំព័រទី២៩ នៃប្រតិចារឹក លោកបាននិយាយថា សុន សេន បានធ្វើការជិតស្និទ្ធជាមួយនឹងលោក ហើយបានផ្តល់សេចក្តីណែនាំដល់លោក ។ ដូច្នេះ ខ្ញុំចង់ឲ្យលោក-- ខ្ញុំចង់បង្ហាញនូវចំណុចមួយផ្សេងទៀតដើម្បីឲ្យលោកផ្តល់នូវមតិយោបល់មកឲ្យខ្ញុំគឺជាចំណុចដែលលោក អេតធេសាន់ បានលើកឡើងទាក់ទងទៅនឹងបញ្ហានេះ ។

នេះគឺជាអ្វីដែលលោក អេតធេសាន់ បាននិយាយ។ នៅទំព័រ៩៨ នៃប្រតិចារឹកនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ លោក អេតធេសាន់ បាននិយាយថា ខ្ញុំចង់រំឭកថា សុន សេន គឺជាសមាជិកគណៈអចិន្ត្រៃយ៍ ហើយនិងជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធានអគ្គសេនាធិការយោធារបស់កម្ពុជាប្រជាធិបតេយ្យផងដែរ ។ ដូច្នេះ គាត់មានការទទួលខុសត្រូវជាច្រើន ។ ហើយគាត់គឺជាមនុស្សម្នាក់ដែលរវល់ ឬក៏មមាញឹកខ្លាំងណាស់ ហើយនៅខាងក្រោមបន្តិចទៀត គាត់បាននិយាយថា ក៏ប៉ុន្តែ នៅពេលដែលខ្ញុំពិនិត្យមើលបញ្ជីដែលបានដាក់បញ្ចូលរួមគ្នា ពីខាងការិយាល័យសហព្រះរាជអាជ្ញាគឺបញ្ជីឈ្មោះអ្នកទោស នៅ ស-២១ នោះ យើងសម្គាល់ឃើញថា មានបុគ្គលមួយ ចំនួនមិនអាចត្រូវបានចាត់ទុកជាមនុស្សសំខាន់ទេ បើទាក់ទងទៅនឹងការទទួលខុសត្រូវ ឬក៏ឋានៈរបស់គេនោះ ។ ហើយឥឡូវនេះនៅបន្ទាត់លេខ១៩ មានចំនួនមនុស្សជាច្រើនត្រូវបានចប់នៅក្នុងកន្លែងសួរចម្លើយ ហើយនិងត្រូវបានគេប្រហារជីវិតដោយយោងទៅតាមការចោទប្រកាន់ថាគេនុំងគឺជាសមាជិករបស់*សេអ៊ីអា*ឬក៏ *កាហ្សេបេ*

ដូច្នេះ ជាការពិបាកក្នុងការពន្យល់ថា អ្នកដែលមានការទទួលខុសត្រូវ កម្រិតទាបដែលសំខាន់បែបនោះ ដូចជា សុន សេន ចាត់ទុក រៀបចំពេលវេលាដើម្បីធ្វើការសួរចម្លើយ ឬក៏ធ្វើការប្រហារជីវិតអ្នកទោសប្រភេទនេះណាស់ ។ ដូច្នេះ សំណួររបស់ខ្ញុំគឺដូចខាងក្រោមនេះ៖

តើនោះគឺជាករណីដូចដែលលោក អេតធេសាន់ បាននិយាយទេ? ដែលថា សុន សេន គឺគាត់មិនមានជាប់ពាក់ព័ន្ធទៅនឹងចម្លើយសារភាពនោះទេ ហើយក៏មិនពាក់ព័ន្ធទៅនឹងការប្រហារជីវិតដែរ ហើយតាមពិតទៅគឺមានតែលោកទេ ដែលជាអ្នកចេញសេចក្ដីសម្រេចបែបនោះ ដោយមិនចាំបាច់មាន នរណាគេត្រួតពិនិត្យពីលើទេ ទាក់ទងទៅនឹងការសួរចម្លើយ ទាក់ទងទៅនឹងចម្លើយសារភាព ជាដើម ។ ហើយនិងទាក់ទងការប្រព្រឹត្តទៅលើមនុស្សដែលមិនមែនសំខាន់នៅក្នុង ស-២១ នោះ ។ តើលោកឯកភាពហ្នឹងអ្វីដែលខ្ញុំបានលើកឡើងនេះដែរឬទេ?

**ឆ៖** លោកមេធាវីជាទីគោរព! និក្ខេបបទរបស់ អេតធេសាន់ ខ្ញុំសុំមិនមានមតិដល់ទេ ទុកឲ្យគាត់និយាយតែតាមតែគាត់ទៅចុះ ។ ដោយឡែក ខ្ញុំសូមបញ្ជាក់រឿងការងារនៅស-២១ នេះ តើវាយ៉ាងម៉េច? ការងារនៅស-២១ នេះ ខ្ញុំរត់តាមបញ្ជាមេគ្រប់មាគ៌ាសកម្មភាពគឺមេចេញ មិនមែនមានន័យថាគាត់មានភារកិច្ចច្រើន ហើយគាត់ធ្វើមិនកើត ខ្ញុំទេជាអ្នកធ្វើហ្នឹងមិនមែនទេ ។ សូមបញ្ជាក់ថា មេខ្ញុំមែនភារកិច្ចច្រើន មែន ។ ឋានៈគាត់ជាសមាជិកអចិន្ត្រៃយ៍មជ្ឈិមបក្សបុគ្គលទីប្រាំពីរ នេះច្បាស់លាស់ ។ ក្នុងជួរនាទីរដ្ឋាភិបាល គាត់ជាឧបនាយកទីបី ក្នុងការងារយោធាគាត់ជានាយអគ្គសេនាធិការផង និងជារដ្ឋមន្ត្រីក្រសួងការពារប្រទេសទៀត ខាងសន្តិសុខ គាត់ទទួលខុសត្រូវខាងសន្តិសុខទូទាំងប្រទេសនេះឯកសារបញ្ជាក់ ។ ខ្ញុំសុំទោស ខ្ញុំមិនអានទេ ឯកសារហ្នឹងយើងស្គាល់អស់គ្រប់ៗគ្នាច្រើនហើយ គឺឯកសារកិច្ចប្រជុំអចិន្ត្រៃយ៍មជ្ឈិមបក្ស ថ្ងៃ០៩ តុលា ១៩៧៥ ទំព័រទីមួយ ក្រោមគេបំផុតនោះ សុន សេន ទទួលភារៈសេនាធិការ និងសន្តិសុខ នេះវាបញ្ជាក់អ៊ីចឹង ។ ដូច្នេះ ការងារមេខ្ញុំច្រើន ។ ក៏ប៉ុន្តែ អ្នកណាមានឥទ្ធិពលលើអ្នកណា? អ្នកណាបញ្ជាអ្នកណា? មេខ្ញុំអត់បណ្ដោយឲ្យខ្ញុំធ្វើសេរីបានទេ ។ ជួបខ្ញុំរាល់ថ្ងៃតាមដានការងារតាមទូរស័ព្ទ ណែនាំគ្រប់បញ្ហា កែតម្រូវគ្រប់បញ្ហា នេះជារឿងពិត ។

រឿងមួយទៀត រឿងសម្លាប់រឿងចាប់ ន៎ រឿងសម្លាប់ រឿងចាប់ រឿងសួរចម្លើយ វាជារឿងដែលមានចែងនៅក្នុងសេចក្ដីសម្រេចថ្ងៃ៣០ មីនា ១៩៧៦ ។ អ្នកណាខ្លះ មានសិទ្ធិសម្រេចកម្ទេច ចុងបំផុតនៅក្នុងជួរកងទ័ពមជ្ឈិមសេនាធិការសម្រេច។ ដូច្នេះ សេនាធិការគាត់អ្នកសម្រេច ។ ដូច្នេះ អាប្អូនក្រុមហ្នឹង នេះច្បាស់ តែអាហ្នឹងវាបញ្ជាឲ្យចាប់ហើយ ម្ចាស់អង្គភាពត្រូវតែចាប់ៗឲ្យស្ងាត់កុំឲ្យតដែបាន

បញ្ជូនទៅមន្ទីរនគរបាល គនរបាលដល់ហើយ ជាគោលការណ៍ត្រូវតែវៃស្លរចម្លើយ នេះពិត ។ អ្នកណាប្រកែកមិនធ្វើការងារនេះ អ្នកឯងចាត់ទុកជាក្បត់ អ្នកឯងត្រូវតែប្រហារជីវិត នេះជារឿងពិត ។ គោល-ការណ៍វាកំណត់មកអ៊ីចឹង រឿងលម្អិតគាត់ជួបខ្ញុំប្រចាំថ្ងៃ គេហៅៗថា “មាគ៌ាសកម្មភាព” ដូច្នេះ ខ្ញុំសូមបញ្ជាក់ឡើងវិញ មិនមែនខ្ញុំធ្វើហើយ សុន សេន មិនដឹងអី ដោយសារការងារច្រើនទេ មេខ្ញុំការងារច្រើនមែន ច្រើនពិត ឈ្លាសវៃៗហើយចំណាស់របស់គាត់ គាត់បងខ្ញុំដប់ពីរឆ្នាំ នេះជម្រាបអ៊ីចឹង ខ្ញុំច្បាស់របស់ខ្ញុំ ។ សូមបញ្ជាក់អ៊ីចឹង ។ និយាយនេះ មិនមែនបានន័យថា ខ្ញុំឆ្លើយដាក់លើមេទាំងស្រុងទេ ប៉ុន្តែនិយាយឲ្យឃើញ តើខ្ញុំទទួលខុសត្រូវប៉ុនណាចំពោះឧក្រិដ្ឋកម្មនេះ? តើមេគាត់បញ្ជាមកវាយ៉ាងម៉េច? មាគ៌ាវាយ៉ាងម៉េច? នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** សំណួរចុងក្រោយ យើងបាននិយាយជាច្រើន ហើយលោកបានពិភាក្សាយ៉ាងច្រើនជាមួយនឹងចៅក្រម ឡាវែន៍ និងលោកប្រធាន កាលពីសប្តាហ៍មុនអំពីបញ្ជីឈ្មោះទាំងប្រាំមួយនៃអ្នកដែលត្រូវបានគេដោះលែង ហើយលោកបានពន្យល់ជាច្រើនទាក់ទងទៅនឹងចំណុចនោះ ដូច្នេះខ្ញុំមិនចាំបាច់និយាយទៀតទេ ។ បញ្ជីនោះ គឺជាការបង្ហាញថាមានមនុស្សជាង១៦០នាក់ ត្រូវបានដោះលែង ហើយនៅក្នុងចម្លើយរបស់លោក លោកថាបញ្ជីនោះឯងគឺមិនបង្ហាញ មិនធ្លាប់បានបង្ហាញនូវការពិតនោះទេ ពីព្រោះតាមការពិតគឺមិននរណាគេម្នាក់ត្រូវបានដោះលែងពីស-២១ ទេ ។ ដូច្នេះ ខ្ញុំចង់លើកឡើងនូវការសន្និដ្ឋានមួយ ដើម្បីឲ្យលោកពិចារណា ។ ខ្ញុំធ្វើដូច្នេះ គឺតំណាងឲ្យកូនក្តីរបស់ខ្ញុំ ដូចជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានមានបងប្អូនសាច់ញាតិបានបាត់បង់ខ្លួននៅទីនោះ ។ នៅពេលនុ៎ង គឺលោកបានបដិសេធមិនទទួលស្គាល់ថា អ្នកអស់ទាំងនុ៎ងជាង១៦០នាក់ហ្នឹង ត្រូវបានគេដោះលែងពីស-២១ ។ គឺបញ្ជីនេះមានការបង្ហាញថា គឺមិនមែនមិនមានលទ្ធភាពក្នុងការដោះលែងនរណាម្នាក់ពីស-២១ នោះទេ ពីព្រោះលោកមិនចង់ឆ្លើយ ហើយលោកយល់ថានេះគឺជាសំណួរមួយដែលធ្វើឲ្យលោកមានការអៀនខ្មាស ។ ហេតុអ្វីបានជាលោកមិនដោះលែងមនុស្សនៅស-២១ ដែលជាមនុស្សមិនមានកំហុស ហើយដែលលោកខ្លួនឯងផ្ទាល់បានដឹងថាលោក ដឹងថាគេហ្នឹងមិនមែនជាមនុស្សមានកំហុសនោះទេ តើលោកទទួលស្គាល់ដូច្នេះទេ?

[១០:២០:០៧]

**ឆ៖** ខ្ញុំជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំសូមញែកបញ្ហាបញ្ជីប្រាំមួយនេះ ជាពីរផ្នែក ។ បញ្ជីមួយ គឺជាបញ្ជីដែលធ្វើនៅក្នុងរយៈកាលឆ្នាំ១៩៧៧ គឺធ្វើនៅក្នុងខែ១១ ឆ្នាំ១៩៧៧ ។ បញ្ជីនេះខ្ញុំធ្វើលេខា

ស-២១ ហើយ មនុស្សមួយរយនាក់ បក្សសម្រេចប្រាប់មកឲ្យខ្ញុំថា មនុស្សមួយរយនាក់ ខាង៩២០ផ្ញើទៅឲ្យមិត្ត មិត្តឲ្យគេកម្ទេចទៅ ។ មិត្តអស់នុ៎ង ជាយុទ្ធជនកងពល៩២០ មកដល់ស-២១ ថ្ងៃ២៣ ខែ១១ ១៩៧៧ មិត្តហ៊ី បែបអារម្មណ៍គាត់នៅជាប់ថាដោះលែងហ្នឹង ជាយុទ្ធវិធីដែលបក្សប្រើតាមល្បែងលេងសើចរបស់ ណាត នោះ ។ គាត់សរសេរមកខ្ញុំ គាត់ថាឈ្មោះដោះលែង នៅថ្ងៃ២៦ ខែ១១ ផ្នែកកងពល ៩២០ គាត់សរសេរមកអ៊ីចឹង ។ ខ្ញុំឃើញទាញជក់ក្រហមយកទៅចារខ្វាច់សម្រាប់ដក នេះឯកសារបើសិនជាលោកមេធាវីត្រូវការ ខ្ញុំនឹងសុំអនុញ្ញាតលោកប្រធាន បញ្ចាំងនៅលើអេក្រង់ ចំណារខ្ញុំថាសម្រាប់ដក ។ ដល់ចុងបញ្ជីនោះ មិត្តហ៊ី គាត់ចារ ។ ពេលណាគាត់អនុវត្តបញ្ជាខ្ញុំចប់ តាមសេចក្តីសម្រេចពីខាងលើហើយ មិត្តហ៊ី គាត់ចារ បានដកចេញឈ្មោះដោះលែងអស់ហើយ ថ្ងៃ២ ធ្នូ ១៩៧៧ ។ បញ្ជីនេះឈ្មោះបញ្ជី D59/4 ចុចប៊ុន្មានទេ ចុច10 អូ! ចុច8 ។ បញ្ជីនេះ ឈ្មោះបញ្ជី D159/4.10 ហ្នឹងច្បាស់លាស់ ។ បញ្ជីនេះគ្មានរឿងដោះលែងទេ។ នៅក្រោមការគ្រប់គ្រងផ្ទាល់របស់ខ្ញុំស-២១ ។ ខ្ញុំទទួលបញ្ជាពីមេមកផ្ទាល់ ខ្ញុំកែតម្រូវមិត្តហ៊ី អត់មានដោះលែងទេ ។ នេះបញ្ជីនៅហ្នឹង បញ្ជីផ្នែកទីពីរៗ ឈ្មោះវាថា បញ្ជី D57 អានិច 003 ឬហៅថាបញ្ជី D14.124 មានឈ្មោះមនុស្ស៤៩នាក់ បញ្ជីនេះមានចំណងជើងថា “មនុស្សដោះលែងនៅក្នុងអង្គភាពកងអនុៗសេនាធំ៤៤ វរសេនាតូប៩៦ កងពល៧០៣” តែកងពល៧០៣ ហ្នឹង ម៉េចក៏បញ្ជីនេះមកនៅឯស-២១ ។ ភស្តុតាងដែលថាបញ្ជីនេះវាមកនៅស-២១ នេះ ចំណារ TSL430 វាបញ្ជាក់ថាអាបញ្ជីនេះ វាមកនៅស-២១ យើងចាប់អារម្មណ៍បញ្ហានេះភ្លាម ។ ហើយតទៅទៀត យើងត្រូវចាប់អារម្មណ៍បញ្ហាដែលខ្ញុំធ្លាប់ធ្វើការជាមួយមេ ហើយធ្លាប់ដឹងរឿងរ៉ាវពីមិត្តម៉ុន, យូ ប៉េងគ្រី ឆ្លើយ វាមានជាប់ឈ្មោះពីរនាក់ នៅលេខរៀងទី១៨ និងរៀងទី៣៦ ដែលណាតរាយការណ៍ជូនមេ ថាពីរនាក់នេះរកធ្វើឃាតគាត់ គាត់បានបើកភ្លើងឡានឲ្យភ្លឺ អាពីរនាក់នោះ រត់ជែងដើរ គាត់រាយការណ៍មិនទាន់ចប់ផង មេកំហែង គាត់កំហែងណាតធ្ងន់ដែរថ្ងៃណោះ គាត់ថាចាប់មនុស្សព្រោះមូលហេតុសុវត្ថិភាពផ្ទាល់មហាបុគ្គល កំហឹងគាត់ ។ ហើយម៉្យាងទៀតសូមបញ្ជាក់ថា សុន សេនស្តីឲ្យលេខានៅមុខអនុលេខាជាបញ្ហាកម្រណាស់ ខ្ញុំនៅហ្នឹងធ្វើការជាមួយគ្នា គ្នាបីនាក់ ។ រួចអារឿងនេះ វាទាក់ទងនៅក្នុងបញ្ជីនេះ បញ្ជី-- នៅក្នុងលេខរៀង១៨ និងលេខរៀង៣៦ ដូច្នេះហើយបានខ្ញុំសន្និដ្ឋានថាបញ្ជីនេះ ពាក់ព័ន្ធនឹងរឿងឧបាយកល ណាត ហើយ ហើយខ្ញុំសូមបញ្ជាក់ជូនលោកឲ្យច្បាស់ថា បញ្ជីនេះស៊ីញេនៅថ្ងៃ២០ ខែ១២ ១៩៧៥ ។ ថ្ងៃ២០ ខែ១២ ១៩៧៥ ទូទាំងប្រទេស កសិករក៏មានពួកមានក្រុមមានកង ។ កម្មករក៏មានពួក មានក្រុម មានកង ។ មន្ទីរក៏មានពួក មានក្រុម មានកង ។

យោធាក៏មានពួក មានក្រុម មានកង ។ យើងដោះលែងទៅឯណា ដែលអង្គការមិនដឹងនោះ ត្រូវតែឆ្លងតាមអង្គការ ។ ណាត ខ្លួនឯង អង្គការឬអី មិនមែនអង្គការទេ ។

[១០:២៦:០៤]

ដូច្នេះ គ្មាននរណាមានសិទ្ធិដោះលែង គ្មានមាត់ឯណាឲ្យដោះលែងអ្នកទោសទេ ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង ខ្លាំងគឺអត់ដោះលែង ។ ដូច្នេះបញ្ជីនេះ ដល់វិភាគទៅខ្ញុំទទួលស្គាល់ថា មនុស្ស៤៩នាក់នេះជារឿងផ្សេង គឺរឿងសម្លាប់គេហើយ ណាត ខ្លាចមានរឿងដោយសារខ្លួនឯងចេះតែដើរចាប់គេពាសវាលពាស់កាល ក៏កាយកប់ដីលុបនេះ ។ ឯបញ្ជីបីផ្សេងទៀតក៏អ៊ីចឹងដែរ បីបួនផ្សេងទៀតក៏អ៊ីចឹងដែរបួនផ្សេងទៀតក៏អ៊ីចឹងដែរ ខ្ញុំមិនរាប់ទេបញ្ជីនេះ ជួនអីមានឈ្មោះម្នាក់ ពីរបញ្ជីមានឈ្មោះម្នាក់ៗ ហើយបញ្ជីផ្សេងពីរផ្សេងទៀត មានឈ្មោះប្រាំ១នាក់ ណ៎ា ខ្ញុំសូមមិនបញ្ជាក់ដល់ទេ វា១យូរណាស់ ។

ដូច្នេះ សរុបមកមនុស្សទាំងប៉ុន្មាននេះ ខ្ញុំឃើញច្បាស់ វិភាគទៅឃើញច្បាស់ ដូច្នេះខ្ញុំមិនវិភាគថាដោះលែងទេ ខ្ញុំបាននិយាយអ៊ីចឹង ខ្ញុំថាឧក្រិដ្ឋកម្មរបស់ខ្ញុំទៅលើមនុស្សជាងមួយម៉ឺននាក់ ខ្ញុំអត់យកអាបញ្ជីឆ្កួតពីរនេះទៅធ្វើជាលេសបិទបាំងទេ ។ ដំរីស្លាប់ពាក្យខ្មែរ "ដំរីស្លាប់យកចង្អេរទៅបាំង" បាំងអត់បានទេ នេះមិនមែនជាចង្អេរទៅបាំងឯណា ។ បញ្ជីពីរសន្លឹកនេះ ពីរ១បញ្ជី ដូចជាកូនស្លឹកអំពិលពីរស្លឹកនេះ យកទៅបាំងដំរីងាប់ម៉េចបាន ។ អាហ្នឹងខ្ញុំអត់បិទបាំងទេ ឧក្រិដ្ឋកម្មរបស់ខ្ញុំវាមាន ខ្ញុំទទួល ត្រង់ថាដោះលែង ខ្ញុំអត់ទទួលថាដោះលែងទេ គឺណាត សម្លាប់គេរួចទៅហើយ ខ្ញុំឲ្យទៅសម្លាប់គេរួចហើយតាមបញ្ជាមេ ឲ្យ១ខ្ញុំទៅថាម៉េច? ដូច្នេះសរុបមក សម្លាប់ ចំពោះបញ្ជីទាំងប្រាំមួយនេះ គឺពិត ។ ដោះលែង ក្នុងបញ្ជីប្រាំផ្សេងទៀត គឺមិនពិត ។ ឯចំណែកខ្ញុំ១បានចាររបស់ខ្ញុំហើយ ថាអត់សម្រាប់ដក១ ។ សរុបមកវិញ ខ្ញុំសុំមានមតិប៉ុណ្ណោះ អំពីរឿងដោះលែងក្លែងក្លាយ ។

**លោក អាឡាំង វ៉ែនណឺ៖**

ខ្ញុំអស់សំណួរទៀតហើយ សូមអរគុណចំពោះការឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមចូលវិញ ហើយបន្តកិច្ចដំណើរការពិភាក្សាដេញដោលតទៅទៀត ដែលលំដាប់បន្ទាប់នេះ គឺជាវេទិការបស់មេធាវីការពារក្តីដែលត្រូវមានការសំណួរសួរដេញដោលពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលបានកំណត់ធ្វើសវនាការនេះ។

*[សវនាការសម្រាកពីម៉ោង ១០:២៨នាទី ដល់ម៉ោង ១០:៥១នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលបន្តទៀត ។ ហើយអញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោក លោកស្រីចៅក្រម លោក ការ សាវុត្ថ និងតាំងសំណួរមុន ប៉ុន្តែនៅក្នុងដំណាក់កាលនេះ ខ្ញុំសូមជម្រាបអង្គសវនាការជាផ្លូវការថា ចំពោះទាក់ទងទៅនឹងមូលហេតុផ្សេងៗ ដោយសារខ្ញុំត្រូវចាកចេញនៅយប់នេះ ដោយសារបញ្ហាគ្រួសារ ។ ដូច្នេះ ខ្ញុំសូមសួរអង្គសវនាការ ថាតើអាចធ្វើការរៀបចំកិច្ចប្រជុំបច្ចេកទេសនៅរសៀលនេះដែរ ឬទេ? នៅពេលដែលយើងបញ្ចប់ការតាំងសំណួររបស់យើង ។ យើងយល់ស្របការតាំងសំណួរទៅកាន់កូនក្តីរបស់ខ្ញុំត្រឹមម៉ោងដប់ពីរ ឬក៏ប្រហែលជាត្រឹមម៉ោងពីរ ។ ដូច្នេះហើយយើងមានពេលនៅសល់នៅពេលរសៀល ដូច្នេះ យើងប្រហែលជាបញ្ចប់ការតាំងសំណួររបស់ខ្ញុំត្រឹមម៉ោងពីរ នេះជាសំណើរបស់ខ្ញុំជូនអង្គសវនាការ ។ ដូច្នេះ ថាតើយើងអាចរៀបចំកិច្ចប្រជុំសវនាការនៅក្នុងថ្ងៃរសៀលនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា! តើលោកមានយោបល់យ៉ាងម៉េចទេ? លើសំណើសុំរបស់មេធាវី ហ្វ្រង់ស្វ័រ រូ ដែលមេធាវីការពារជនជាប់ចោទ ដែលសុំឱ្យមានការពិចារណាក្នុងការកែប្រែលើកាលវិភាគនៃកិច្ចប្រជុំរៀបចំដំណើរសវនាការ ដែលយើងគ្រោងធ្វើនៅរសៀលថ្ងៃព្រហស្បតិ៍ ទី២៥ នោះ ឱ្យមកធ្វើនៅរសៀលនេះវិញ ។ ដោយសារកាលវេលាដែលយើងបានគណនាទៅឃើញថា យើងបានដំណើរការចប់មុនគ្រោងទុក ហើយហេតុផលមួយទៀត គឺគាត់ត្រូវមានធុរៈរឿងគ្រួសាររបស់គាត់ ។ តើលោកសហព្រះរាជអាជ្ញា មានយោបល់យ៉ាងម៉េចដែរបញ្ហានេះ?

**លោក យ៉េត ចរិយា៖**

អរគុណលោកប្រធាន ចំពោះសំណើនេះ ខាងសហព្រះរាជអាជ្ញាឯកភាពទាំងស្រុង ។

**ប្រធានអង្គជំនុំ៖**

ចុះខាងមេធាវីការពារតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីវិញ តើមានយោបល់យ៉ាងម៉េចដែរ អំពីការស្នើសុំរបស់មេធាវី ហ្វ្រង់ស្វ័រ រូ អំពីការលើកដំណើរការរៀបចំប្រជុំ-- ដំណើរការកិច្ចប្រជុំរៀបចំសវនាការ ដែលយើងគ្រោងធ្វើនេះ? ហើយសុំមកកែប្រែមកធ្វើនៅរសៀលនេះវិញ ដោយមូលហេតុ

គាត់មានធុរៈត្រូវចាកចេញនៅយប់នេះ ទៅត្រឡប់ទៅស្រុករបស់គាត់ ដោយសារមូលហេតុបញ្ហាគ្រួសារនោះ ។

[១០:៥៤:៥០]

**លោក អាឡាំង វ៉ែនណឺ៖**

គឺយើងមិនអាចពិភាក្សាក្នុងចំណោមក្រុមយើងទេ ដោយសារតែយើងទើបតែទទួលបានព័ត៌មាននេះ ប៉ុន្តែយើងអត់មានការជំទាស់ទៅលើបញ្ហានេះទេ ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សិនស្គី៖**

ខ្ញុំនឹងមិនជំទាស់ទៅលើសំណើនេះទេ ប៉ុន្តែខ្ញុំសូមរក្សាសិទ្ធិរបស់យើងខ្ញុំក្នុងការផ្តល់ជំហរផ្សេងៗទាក់ទងទៅនឹងបញ្ហាចោទនៃការដកសាក្សីពីបញ្ជី ។ ដូច្នេះ យើងសូមឮ្យរសិទ្ធិរបស់យើង ដើម្បីផ្តល់ជាជំហររបស់យើងនៅពេលក្រោយ ដោយសារតែយើងមិនទាន់មានពេលវេលាគ្រប់គ្រាន់ទៅលើការរៀបចំជំហររបស់យើងនៅលើករណីនេះ ។ ដូច្នេះ គឺខ្ញុំសូមរក្សាសិទ្ធិលើបញ្ហានេះ ។

**លោក គីម ម៉េងឃី៖**

សូមគោរពលោកប្រធាន! មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី មិនជំទាស់ទៅនឹងការលើកឡើងរបស់មេធាវីការពារទេ ។ ក៏ប៉ុន្តែស្នើសុំ បើអាចធ្វើបានការប្រជុំគួរតែមានរយៈពេលយូរគឺអាចចាប់ពីម៉ោងមួយ ឬក៏មួយនិងសាមសិបនាទីទៅ គឺជាការល្អ ប្រសើរជាងការចាប់ផ្តើមនៅម៉ោងពីរ ឬក៏បើអាចបានសុំឲ្យមេធាវីការពារក្តីអាចបញ្ចប់សំណួររបស់ខ្លួននៅព្រឹកនេះតែម្តង ដើម្បីឲ្យពួកយើងមានពេលគ្រប់គ្រាន់នៅក្នុងការពិចារណាទៅលើបញ្ហាដែលត្រូវពិភាក្សានៅក្នុងកិច្ចប្រជុំនេះ ។ សូមអរគុណ ។

**លោក គង់ ពិសី៖**

សូមគោរពលោកប្រធាន ហើយសូមគោរពអង្គជំនុំជម្រះទាំងអស់ ។ ខ្ញុំបាទក្នុងនាមជាមេធាវីតំណាងឲ្យខាងក្រុមបួន ក៏ដូច្នេះដែរ គឺថាមិនមានការជំទាស់អីទេក្នុងការស្នើសុំរបស់គាត់ ។ ប៉ុន្តែគួរតែកត់សម្គាល់ផងដែរ គឺថាមេធាវីការពារគួរតែខិតខំប្រឹងប្រែងផ្នែកខាងវិជ្ជាជីវៈរបស់ខ្លួន ដើម្បីការពារកូនក្តីរបស់ខ្លួនឲ្យបានពេញលេញ ពីព្រោះថា ឧទាហរណ៍ជាក់ស្តែងលើកឡើងថា នៅពេលដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់មិនបានបង្ហាញឯកសារទាំងឡាយទៅដល់មេធាវីការពារមុន ។ តាមការពិតឯកសារទាំងឡាយមាននៅក្នុងសំណុំរឿងទាំងអស់ មេធាវីការពារគួរតែយកឯកសារនោះយកមកពិនិត្យ

មើលឱ្យបានត្រឹមត្រូវ នេះគឺជាចន្លោះប្រហោង ដែលមេធាវីការពារតែងតែសុំផ្អាកកាលពេលវេលានេះ។ សូមអរគុណ ។

[១០:៥៧:៤៤]

**ប្រធានអង្គជំនុំ៖**

អរគុណដែលបានចាប់អារម្មណ៍ក្នុងបញ្ហានេះ ហើយតាមការលើកឡើងនេះ ខ្ញុំយល់ថា មិនមានការជំទាស់អីជាធំដុំទេ ។ អ៊ីចឹង គឺអង្គជំនុំជម្រះសម្រេចថា យើងលើកកាលវិភាគនៃការប្រជុំរៀបចំសវនាការដែលយើងគ្រោងធ្វើនៅរសៀលថ្ងៃព្រហស្បតិ៍ ទី២៥ នោះ យើងយកមកដាក់ធ្វើនៅរសៀលនេះវិញ ។ ហើយអង្គជំនុំជម្រះក៏សង្ឃឹមជឿជាក់លើមេធាវីការពារក្តីដែរ នឹងប្រឹងប្រែងក្នុងការតាំងសំណួរដេញដោលដល់កូនក្តីរបស់លោកឱ្យបានឆាប់ ហើយចំបញ្ហា ដើម្បីសន្សំពេលវេលាទៅដំណើរការរៀបចំជជែកពិភាក្សា អំពីបច្ចេកទេសក្នុងរៀបចំដំណើរការសវនាការរបស់យើងតទៅមុខទៀត ។ ធ្វើយ៉ាងម៉េចឱ្យបានឆាប់រហ័ស ដែលយើងបានគ្រោងធ្វើរួចហើយនោះ ។

ដោយឡែកកាលវិភាគ ដែលយើងគ្រោងហ្នឹង គ្រាន់តែប្តូរទេ បានន័យថា នៅរសៀលថ្ងៃព្រហស្បតិ៍ទី២៥ នោះ យើងប្តូរមកធ្វើនៅរសៀលនេះ ហើយចំណែកឯរសៀលនោះយើងនឹងធ្វើសវនាការលើអង្គហេតុមន្ទីរសន្តិសុខព្រៃស តាមកម្មវិធីដែលយើងបានគ្រោងទុក ។ គ្រាន់តែមានការប្រែប្រួលប៉ុណ្ណឹង ។

ជាកិច្ចបន្តនេះ សូមអញ្ជើញ សូមប្រគល់វេទិកានេះជូនទៅមេធាវីការពារក្តី ដើម្បីសួរដេញដោលដល់កូនក្តីរបស់លោក ។ សូមអញ្ជើញលោកមេធាវី ។

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សូមអរគុណលោកប្រធាន ។ លោក ឌុច តើ ស-២១ និង ម-២១ ខុសគ្នាយ៉ាងណាខ្លះ? សូមលោកពន្យល់ឱ្យបានច្បាស់ ។

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី ស-២១ ឬនិយាយឱ្យពេញពាក្យរបស់គេថា មន្ទីរ ស-២១ នេះ ។ អង្គសវនាការ ហើយនិងទាំងអស់គ្នាឮយូរមកហើយ ខ្ញុំសូមបញ្ជាក់ដោយពន្យល់ថា មន្ទីរស-២១ នេះវាជាអង្គភាពមួយដែលអចិន្ត្រៃយ៍បក្ស ចាត់តាំងឡើង ហើយដឹកនាំដោយផ្ទាល់ស្របទៅតាមគោលការណ៍ ដែលមានចែងនៅក្នុងមាត្រាទី៨ នៃលក្ខន្តិកៈបក្ស ។ ហើយសមាជិកអចិន្ត្រៃយ៍ដែលចុះមកក្តាប់

ស-២១ ដោយផ្ទាល់នោះគឺ សុន សេន បុគ្គលទីប្រាំពីររបស់បក្សកុម្មុយនីស្តកម្ពុជា ។ មនុស្សទាំងអស់នៅ ស-២១ ហៅ សុន សេន ថា អង្គការ នេះរឿងមន្ទីរ ស-២១ ។

[១១:០១:១១]

ឯចំណែក ម-២១ នេះ វាលេចឡើងនៅក្នុងអង្គប្រជុំយើងទាំងមូលប៉ុន្មានថ្ងៃនេះ នៅក្នុងឯកសារលេខ E5/2.10 ដែលខ្ញុំសរសេរតាមបញ្ជា ណាត ទាមទារសុំចាប់ អាំង លី ហើយនិង ព្រំ ឌួង ហើយនិងទាមទារឲ្យអង្គការតាមដាន ស សៅ តទៅទៀត ។ ដូច្នេះ ម-២១ វាទើបតែលេចនៅក្នុងសវនាការនេះទេ ។ ខ្ញុំសូមបញ្ជាក់ថា ម-២១ នេះ វាមិនមែនជាអង្គការដែលអចិន្ត្រៃយ៍មជ្ឈិមបក្សចាត់តាំងទេ វាគ្រាន់តែលេខាធិការដ្ឋានផ្ទាល់របស់ ណាត ។ ដែល ណាត គាត់ប្រឌិតឡើងក្នុងរយៈពេលដែលគាត់ធ្វើជាប្រធាន ហើយគាត់ខ្លួនឯងតែងតាំងខ្លួនជាអង្គការ នេះជារឿងពិត ។ ខ្ញុំសូមអនុញ្ញាតជូនភស្តុតាងមួយដែលមាននៅក្នុងលេខ D14140 ឬក៏លេខកូដ TSL4479 ដែលក្រោយមក ដោយបណ្តឹងរដ្ឋប្បវេណី E2/56.2 លោកយកទៅប្រើ ។ ក្នុងនេះ គឺ ណាត ឲ្យបង ម៉ម ណៃ សរសេរសំណួរទៅលើឈ្មោះ យន់ លឿន ហើយដល់ចុងបញ្ចប់បង ម៉ម ណៃ ត្រូវ ណាត បង្គាប់ឲ្យសរសេរថា “ដូច្នេះ សូមស្នើអង្គការអនុគ្រោះដោះលែងឈ្មោះនេះ ។ ថ្ងៃ២៥ ខែធ្នូ ១៩៧៥ ម-២១” នៅទំព័រខាងដើម ណាត សរសេរ “យល់ព្រមឲ្យដោះលែង” ស៊ីញ៉េ ណាត ហើយថ្ងៃ២១ ខែ១២ ។ លោកប្រធានជាទីគោរព! ខ្ញុំបាទសូមអនុញ្ញាតឲ្យគេបញ្ចាំងលើឯកសារមួយសន្លឹកនេះលើអេក្រង់ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារនោះបញ្ចាំងនូវលើ *ស្លាយ* ។

[១១:០៤:២១]

**ជនជាប់ចោទ៖**

សូមគោរពអានជូនលោកប្រធាន ហើយនិងអង្គសវនាការថា “សូមស្នើអង្គការអនុគ្រោះដោះលែងឈ្មោះនេះ ។ ថ្ងៃ២៥ ខែ១២ ១៩៧៥ ម-២១” អក្សរនេះ ជាអក្សរបង ម៉ម ណៃ ។ លោកប្រធានជាទីគោរព ខ្ញុំសូមឲ្យគេបញ្ចាំងត្រឡប់ទៅទំព័រដើម ដែលមានស៊ីញ៉េ ណាត ។ “យល់ព្រមឲ្យដោះលែង” នេះស៊ីញ៉េ ណាត “ថ្ងៃ២១ ខែ១២-- ២៦ ខែ១២” សូមចប់ ។ សូមជម្រាបបញ្ជាក់ជូនលោកប្រធានថាម-២១ នេះមានប្រើនៅ ស-២១ ដោយសារ ណាត គាត់ប្រឌិតឈ្មោះនេះឡើងតែប៉ុណ្ណោះឯង ។ ហ្នឹងខ្ញុំសូមចប់សំណួរទីមួយ ដែលលោកមេធាវី លោកសួរខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

បានហើយៗ បិទ ដកវិញទៅ ។ បាទ សូមអញ្ជើញបន្តសំណួរទៀតបាទ ។

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សំណួរទីពីរ អ៊ីចឹងនរណាខ្លះមានអំណាចនៅម-២១?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី គឺមានតែម្នាក់គត់គឺ ណាត ក្រៅពីនោះគ្មានអ្នកណាមាន អំណាចនៅលើ ម-២១ នោះទេ ។

**ស៖** សំណួរទីបី តាមឯកសារជាច្រើនជាពិសេស E5/2.10 លោកសរសេរលើសំណួមពរសុំ ចាប់ អាំង លី និង ព្រំ ខួង ហើយឲ្យអង្គការតាមដាន សរ សៅ ។ ចុះហេតុដូចម្ដេចបានជាលោកថា លោកអត់អំណាចទៅវិញ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! នៅក្នុងរយៈកាលនោះ ណាត ប្រើឲ្យខ្ញុំសង្ខេបចម្លើយ ដែលកម្មាភិបាលសួរចម្លើយ គេសួររួចហើយ ។ គាត់ឲ្យខ្ញុំសង្ខេបឲ្យខ្លី តែឲ្យមានន័យគ្រប់គ្រាន់ពេញ លេញ ។ ចុងបំផុតគាត់ឲ្យខ្ញុំសរសេរ តាមបញ្ជាគាត់ក្នុងសំណួមពរចាប់ខ្លួន និងតាមដានបុគ្គលមួយ ចំនួន ។ ឧទាហរណ៍ ឯកសារ E5/2.10 ជាភស្តុតាងស្រាប់ ហើយទន្ទឹមនេះក៏មានស៊ីញ៉េខ្ញុំ អក្សរខ្ញុំនៅ លើឯកសារ E5/2.9 និង E5/2.8 ផងដែរ ។ ទន្ទឹមនេះក៏មាននៅលើ E5/2.3 ដែលនៅជាអត្ថបទព្រាង នៅឡើយ។ ក៏ប៉ុន្តែ គ្រាន់តែឯកសារទាំងអស់នោះ មិនមានសរសេរថាម-២១ មានតែឯកសារ E5/2.10 នេះទេ ដែលមានពាក្យថា ម-២១ ។

ដូច្នេះ ណាត ប្រើខ្ញុំច្រើន ក្នុងឋានៈជាស្មៀន ។ ដូចជាៗ ក្នុងឋានៈ-- ដូចជាស្មៀនរបស់គាត់ អ៊ីចឹង ។ នេះសូមបញ្ជាក់ជូនខ្លីប៉ុណ្ណេះថា ណាត ប្រើខ្ញុំជាអនុប្រធាន ស-២១ ក្នុងឋានៈដូចស្មៀន ។ សូម បញ្ជាក់សំណួរទីបីនេះប៉ុណ្ណេះ ។

[១១:០៧:៥០]

**ស៖** អ៊ីចឹងសំណួរទីបីនេះ គឺលោកអត់អំណាចទេ គឺលោកស៊ីញ៉េក្នុងឋានៈលោកជាស្មៀន ដែល គេប្រើ ។ ឥឡូវសំណួរទីបួន អត្ថបទដែលលោកសរសេរសុំចាប់ខ្លួននិងអង្គការតាមដាននោះ ណាត គេ ឲ្យលោកចាត់ចែងយ៉ាងម៉េចតទៅទៀត?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! មិនមែនខ្ញុំជាអ្នកចាត់ចែងតទៅទៀតទេ គឺ ណាត គេជា អ្នកចាត់ចែង ។ ទីមួយគេពួកអង្គុលីលេខវាយអង្គុលីលេខ ចម្លងអត្ថបទខ្ញុំ ។ ហើយគេប្រគល់ឲ្យបង

ម៉ម ណៃ រក្សាទុកអត្ថបទច្បាប់ដើមដែលខ្ញុំសរសេរនេះ ទុកក្នុងបញ្ជីឯកសារ ។ ហើយបន្ទាប់មកគេយកអត្ថបទដែលវាយអង្គុលីលេខហើយនេះទៅឲ្យ មិត្តម៉េង ដើររកចាប់មនុស្ស ។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធានបញ្ចាំងនូវឯកសារមួយចំនួនដូចតទៅ ។ ដំបូងគឺសូមបញ្ចាំងឯកសារលេខកូដ E5/2.9 ត្រង់ទំព័រ 00226279 សូមជម្រាបប្រសាសន៍លោកប្រធាន--

*(អ្នកបកប្រែ៖ សូមឲ្យជនជាប់ចោទនិយាយលេខ ERN ឡើងវិញម្តងទៀតបាទ)*

**ជនជាប់ចោទ៖**

លេខ ERN 0002260279 ខ្ញុំសូមអនុញ្ញាតបញ្ចាំងទំព័រ--

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារពីជនជាប់ចោទបញ្ចាំងស្លាយ ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន ខ្ញុំសូមអានចំណារ ណាត ជូនអង្គប្រជុំ ។ “សមមិត្ត ចាន់ ទុកជាឯកសារចោះ ។ បោះពុម្ពហើយ ២១.១១” ។ ដូច្នេះ ដូចខ្ញុំបានបញ្ជាក់អំមិញអ៊ីចឹង អត្ថបទរបស់ខ្ញុំគាត់ឲ្យគេយកទៅវាយម៉ាស៊ីនអង្គុលីលេខ វាយហើយគាត់ឲ្យច្បាប់ដើមទៅឲ្យ បងចាន់ ទុក ។ នេះគឺសូមបញ្ជាក់ប៉ុណ្ណឹង ។ ហើយទន្ទឹមនេះគាត់ក៏ចាត់ចែងឲ្យមិត្ត ម៉េង ដើរទៅសុំគេចាប់ ។ ខ្ញុំសូមជូនលោកប្រធានអនុញ្ញាតឲ្យបញ្ចាំងឯកសារលេខ E5/2.5។ ត្រង់ទំព័រ 00227473 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារពីជនជាប់ចោទដាក់បញ្ចាំងស្លាយ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ខ្ញុំសូមអនុញ្ញាតអានចំណាររបស់ ណាត ។ “សមមិត្ត ម៉េង ឲ្យសមមិត្តដើរសួររកគ្រប់កង បើមិនយញឲ្យសួរទៅ១១ទៀត ។ សរសេរសំបុត្រក្នុងនាមប្រធានមន្ទីរ ។ ថ្ងៃ០៨ ខែ១០។” ។ ដូច្នេះ ខ្ញុំបញ្ចប់ការអានប៉ុណ្ណោះ នេះថ្ងៃ០៨ ខែ១០ ។ សូមបញ្ចប់ការអានឯកសារប៉ុណ្ណោះ ហើយសូមដំណើរការបញ្ចប់សំណួរទីបួន ដែលលោកមេធាវីសួរខ្ញុំប៉ុណ្ណោះ ។

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សូមអរគុណ សូមសួរសំណួរទីប្រាំ ។ តើផ្ទាល់ខ្លួនលោកបានប្រើ ម-២១ នេះបែបណាផ្សេងទៀត?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំបានប្រើម-២១ នេះនៅក្នុងការសង្ខេបចម្លើយ ។ កាលណាចម្លើយណាមិនច្បាស់លាស់ ខ្ញុំសរសេរត្រឡប់ទៅឲ្យម-២១ បញ្ជាក់ សួរបញ្ជាក់ឲ្យខ្ញុំឡើងវិញ ។ ឧទាហរណ៍នៅហ្នឹងឯកសារ E5/2.2 ខ្ញុំបានចារថា “បានអនុម័ត” បានន័យថាខ្ញុំបានអនុម័ត “បញ្ជូន” គឺ “បញ្ជូនចម្លើយ លៃ សុខា ឈ្មោះ ស្មាន ស្លេះ ទៅម-២១ វិញ ។ មូលហេតុ គឺការសួររបស់គេហ្នឹង វាច្របូកច្របល់” ។ នេះខ្ញុំមានប្រើថែមទៀតនៅក្នុងការឆ្លើយតបនេះ ។

ដូច្នេះ បញ្ហានេះខ្ញុំសូមមិនបានបញ្ជាំងជូនទេ ។ សូមគ្រាន់តែអានចំណារដែលខ្ញុំបានកត់ត្រាទុកមកប៉ុណ្ណេះ ។ បញ្ហានេះវាបញ្ជាំងឲ្យឃើញថា ខ្ញុំមិនមានអំណាចអីទៅគ្រប់គ្រង អាម-២១ នេះទេ ។ បើកាលណាចម្លើយមិនច្បាស់ខ្ញុំត្រឡប់ចម្លើយ ហើយនិងឲ្យគេសួរជនជាប់ចោទហ្នឹងសាថ្មីឲ្យខ្ញុំ ។ នេះខ្ញុំសូមបញ្ចប់បញ្ហានេះប៉ុណ្ណេះ ។

**ស៖** សំណួរទីប្រាំមួយ តើ ណាត បានប្រើ ម៉ម ណៃ ឲ្យសរសេរអ្វីខ្លះ ក្នុងនាម ម-២១?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី ណាត គាត់បានប្រើបង ម៉ម ណៃ ច្រើន ឲ្យសរសេរសំណួរ និងសេចក្តីសារភាពមួយបែបសម្រាប់ឲ្យគាត់ដោះលែងក្លែងក្លាយ ។ ឯកសារដែលខ្ញុំបញ្ជាំងអំមិញនេះ D14140 ឬក៏ហៅថា E2/56.2 នេះ វាជាបញ្ជាក់ស្រាប់ ។ ក្រៅពីនោះមានឯកសារដែលបង ម៉ម ណៃ សរសេរច្រើន ជូនអង្គការ សុំអង្គការដោះលែង ហើយ ណាត ដើរតួជាអង្គការ ។ ដូចឯកសារដែលយើង-- ដែលដើមបណ្តឹងរដ្ឋប្បវេណីលេខ E2/55 ប្រើនៅក្នុង*អានេនិច* (Annex) នៅក្នុងឧបសម្ព័ន្ធចុច២ ដែរ ហើយនិងឯកសារផ្សេងទៀត ។ នេះខ្ញុំសូមបញ្ជាក់បញ្ហានេះ ។

[១១:១៥:៥៨]

**ស៖** សូមអរគុណ សូមសួរសំណួរទីប្រាំពីរតទៅទៀត ។ តើ ណាត បានប្រើឈ្មោះ អង្គភាពអ្វីផ្សេងទៀតទេ ដើម្បីទាមទារចាប់មនុស្ស?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! តាមការសង្កេតឯកសារដែលធ្លាក់មកដល់ដៃខ្ញុំសាឡើងវិញនេះ ។ ខ្ញុំអាចសន្និដ្ឋានបានថា ណាត ប្រើពាក្យថា ម-២១ មួយនេះ ដើម្បីចាប់មនុស្សនៅតំបន់២៥ បានន័យថា ចាប់មនុស្សចេញពីស្រុកស្អាង កោះធំ លើកដែក កៀនស្វាយ ។ ដែលគាត់ធ្លាប់ការទាក់ទងដោយផ្ទាល់ ។ ដោយឡែកទៅខាងភូមិភាគកណ្តាល គាត់ប្រើឈ្មោះមន្ទីរ០៣ ជំនួសវិញ ។ ឯកសារៗលេខ D32/V ពី ERN 173458 ដល់ 173465 ដែលគាត់ប្រើពាក្យ ម-០៣ នេះសូមចាប់មនុស្សពីភូមិភាគកណ្តាល នេះឯកសារនេះ ។ ខ្ញុំសូមមិនបញ្ជាំងទេ យូរដែរ ខ្ញុំគ្រាន់តែសូមបញ្ជាក់ថា ត្រង់ទំព័រ

0017362 សូមទោស ត្រង់ទំព័រ 00173462 គាត់លុបពាក្យខ្ញុំចោល គាត់កែពាក្យខ្ញុំព្រមទាំង គាត់សរសេរទៅមេ ។ ខ្ញុំគ្រាន់តែសូមអានឯកសារនេះប៉ុណ្ណោះ ។

ពាក្យខ្ញុំសរសេរថា "បង០៣ ជាទីគោរព!" បង០៣ ហ្នឹងគឺសំដៅ ណាត ។ គាត់លុបពាក្យខ្ញុំចោល គាត់ចារថា "ប្រវត្តិរូប គៀន ពតង្វូវវ៉ា" នេះនៅខាងលើ ។ ហើយដល់ពាក្យរបស់ខ្ញុំដែរត្រង់ប្រការទីបីត្រង់កថាខណ្ឌទី៣ ខ្ញុំថា "ចាប់ ឬមិនចាប់ស្រេចបងវិភាគសម្រេចចុះ ។ ធ្វើនៅថ្ងៃទី២៧ ខែ១១/១៩៧៥ ឌុច" ។ គាត់លុបពាក្យខ្ញុំចោល ហើយគាត់សរសេរ ប្រុងសរសេរទៅបង ខៀវ សរសេរទៅមេ ។ មានអក្សរគាត់ថា "ជម្រាបបងជាទីគោរព ឈ្មោះ គៀន ពត, ង្វូវ វ៉ា យើងខ្ញុំស្នើសូមចាប់បច្ចុប្បន្ននេះក្លែងប្រវត្តិរូបដាក់ថា កម្មករនៅបារាយណ៍ កំពង់ធំ" ។ នេះគាត់កែមួយសារទៅ ដល់ចុងបញ្ចប់គាត់កែទាំងអស់ទៅជាអត្ថបទស្លាតរ នៅទំព័រ 00173461 ខាងលើគាត់ដាក់ "ប្រវត្តិរូប គៀន ពត, ង្វូវ វ៉ា និង ទឹក ប៊ុនឌីម" ។ ខាងក្រោមគាត់សរសេរថា "ធ្វើនៅថ្ងៃ២៩ ខែ១១ ១៩៧៥ មន្ទីរ០៣" ។ នេះវាបញ្ជាំងឲ្យឃើញថា ទៅខាងភូមិភាគកណ្តាលគាត់ប្រើឈ្មោះមន្ទីរ០៣ ។ ហើយចំណារគាត់អត់មានស្នើសុំអ្នកណាទេ តាមរបៀបជាអ្នកផ្តល់ព័ត៌មាន ។ គាត់សរសេរថា នេះអក្សរគាត់ "ទាំងពីរនាក់នេះ យើងរើឯកសារយុវជនប្រឆាំងកុម្មុយនីស្តទៅឃើញ មានឈ្មោះវាជាក់ស្តែង ។ ហត្ថលេខា សែន ៣១ ខែវិច្ឆិកា" ។ ដូច្នេះ គាត់អាចច្រឡំ មិនមែនថ្ងៃ៣១ ខែវិច្ឆិកាទេ ប្រហែលជាថ្ងៃ០១ ខែធ្នូ ។

[១១:២០:00]

ឯកសារដែលគាត់ប្រើ ដោយប្រើឈ្មោះ០៣ សំដៅទៅភូមិភាគកណ្តាល ។ ប៉ុន្តែ បើតាមខ្ញុំសន្និដ្ឋានទៀត ឯកសារទាំង៨ទំព័រនេះ វាមាននៅហ្នឹង ស-២១ ទាំងច្បាប់ដើម-- សូមទោស ទាំងច្បាប់បឋម-- ទាំងច្បាប់លើកទីមួយ ហើយនិងច្បាប់កែប្រែសម្រេចជាស្លាតរមានស៊ីញ៉េគាត់នៅក្នុងនេះ ។ ដូច្នេះ ខ្ញុំសន្និដ្ឋានថាប្រហែលជា ណាត មិនបានយកឯកសារនេះទៅប្រើ ដើម្បីចាប់មនុស្សនៅភូមិភាគកណ្តាលដោយមិនឆ្លងតាមមេទេ ព្រោះគាត់លុបពាក្យបងជាទីគោរពហ្នឹងចោលបាត់ទៅហើយ ។ ដូច្នេះ ណាត គាត់ដើរចាប់គេ ចាប់ឯងពាសវាលពាសកាលអ៊ីចឹង ។ នេះឯកសារដែលនៅសល់ វាបង្ហាញឲ្យឃើញអ៊ីចឹង ។ សូមបញ្ជាក់ជូនលោកមេធាវីប៉ុណ្ណោះ ។ សូមចប់ ។

**ស៖** សូមអរគុណ ។ សូមសួរសំណួរទីប្រាំបី ។ បើណាត ចេះតែសម្រេចចាប់គេពាសវាលពាសកាលយ៉ាងនេះ ហេតុដូចម្តេចបានជាអង្គការរបស់លោក គឺ សុន សេន ប៉ុល ពត មិនចាត់វិធានការលើណាត?

**ឌុ៖** ជម្រាបប្រសាសន៍លោកមេធាវី! បើតាមការសង្កេតព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលកើតមានចំពោះណាត មានច្រើន តែពេលនេះ ខ្ញុំសូមលើកតាមព្រឹត្តិការណ៍លំដាប់លំដោយពេលវេលា ដូចតទៅ៖

ព្រឹត្តិការណ៍ទី១ កើតនៅក្នុងខែ១២ ឬក៏ចុងខែ១១ ដើមខែ១២ ។ ពេលនោះមេហៅខ្ញុំ ហើយនិងណាតទៅធ្វើការពីរនាក់ ។ ទៅដល់ ណាត រាយការណ៍ថា មានគេរកធ្វើឃាតគាត់ ណាត មិនទាន់រាយ-ការណ៍ចប់ស្រួលបួលផង មេមិនដឹងជាដឹងរឿងហ្នឹងពីណា កម្រិតណាទេ ច្រឡោតដាក់ ណាត ។ គាត់ថា សម្រេចចាប់មនុស្សព្រោះមូលហេតុសុវត្ថិភាពផ្ទាល់ខ្លួន មហាបុគ្គល ។ សម្ដីមួយម៉ាត់នេះ ធ្វើឱ្យណាត គាត់ស្ងាត់មាត់ ហើយខ្ញុំ ខ្ញុំនៅក្បែរហ្នឹងដែរ ក្នុងឋានៈអនុលេខាដែលមេហៅទៅធ្វើការជាមួយដែរហ្នឹងនៅស្ងៀម នេះជាបាតុភាពទីមួយ ។

[១១:២២:២៦]

បាតុភាពទីពីរ ឯកសារដែលនៅសល់ទាំងប្រាំមួយសន្លឹក ដែលខ្ញុំលើកឡើងនេះ វាបង្ហាញអំពីការដោះលែងក្លែងក្លាយ-- ទាំងប្រាំសន្លឹកៗ សូមទោស ទាំងប្រាំសន្លឹក ដែលខ្ញុំលើកឡើងជូនអង្គសវនាការនេះ វាបង្ហាញអំពីការដោះលែងក្លែងក្លាយ នៅពេលដែលគាត់ដឹងខ្លួនថា អង្គការអាចយល់ នេះពិតព្រឹត្តិ-ការណ៍ទី២ ។ ព្រឹត្តិការណ៍ទី២នេះ ការដោះលែងក្លែងក្លាយនេះ វាចាប់កំណើតពីថ្ងៃ២០ធ្នូ នៅក្នុងឯកសារ D57 ៗAnnex 003 ។ ដូច្នេះ ការដោះលែងក្លែងក្លាយនេះ វាចាប់កំណើតឃើញជាឯកសារដែលនៅសល់ គឺនៅថ្ងៃ២០ធ្នូ ១៩៧៥ ហើយវាទៅបញ្ចប់នៅថ្ងៃ៨ ខែមីនា ១៩៧៦ នៅក្នុងឯកសារ អ៊ូ! ភ្លេចលេខកូដបាត់ទៅហើយ ។ នៅក្នុងឯកសារដោះលែងម្នាក់ មកពីខាងស្មោងនោះ ដូចជាឯកសារ E5/2.8 ។ ដូច្នេះ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទីពីរ គឺ ណាត បង្កើតរឿងដោះលែងក្លែងក្លាយ ដោយសារខ្លួនបានចាប់អត្តនោម័តិ លង់ខ្លួន ដើម្បីលុបដាន ។

ព្រឹត្តិការណ៍ទី៣ ក្នុងខែមីនា ១៩៧៦ អង្គការដក ណាត ចេញពី ស-២១ តាមគោលការណ៍សេចក្ដីត្រូវការចាំបាច់របស់ការងារ ដក ណាត ចេញពី ស-២១ ខែ៣ ។

ព្រឹត្តិការណ៍ទី៤ ដែលមានសារៈសំខាន់មែនទែនក្នុងប្រវត្តិសាស្ត្រ គឺ ប៉ុល ពត អនុម័តបញ្ជាមួយចំនួននៅក្នុងថ្ងៃទី៣០ មីនា ឆ្នាំ១៩៧៦នេះ ត្រង់កថាខណ្ឌទី១ អង្គសវនាការស្គាល់ហើយ ឯកសារហ្នឹងស្គាល់ហួរហែហើយ ។ កថាខណ្ឌទី១ មានចំណងជើងថា “សិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ” ដល់ខែ៤ ថ្ងៃ១៩ ថ្ងៃ២០ ថ្ងៃ២១ អចិន្ត្រៃយ៍ប្រជុំបីថ្ងៃជាប់គ្នា ។ នៅក្នុងសេចក្ដីប្រជុំនេះ ប៉ុល ពត សម្រេច

ព្យួរជើងណាត មិនឲ្យ ណាត កាន់កាប់កម្លាំង ។ ខ្ញុំឯកសារដែលមានថែងអំពី ប៉ុល ពត សម្រេចមិនឲ្យ ណាត កាន់កាប់កម្លាំងហ្នឹង គឺឯកសារលេខ D00694 ខ្ញុំសូមអានតែត្រង់ទំព័រដែលមានពាក្យ ប៉ុល ពត មិនទុកចិត្តណាតនេះច្បាស់លាស់នេះប៉ុននុ៎ង គឺនៅត្រង់ទំព័រ00019145 ខ្ញុំសូមអានលេខERN ឡើងវិញ គឺ 00019145 មានសរសេរថា ក្នុងទំព័រនេះមានសរសេរថា "ឯសមមិត្ត មាន និងសមមិត្ត ណាត គ្រាន់តែជាកម្មាភិបាលសេនាធិការចល័ត ជួយក្នុងសេនាធិការខាងប្រតិបត្តិការប្រយុទ្ធ អត់ក្តាប់កម្លាំងផ្ទាល់ទេ" ដូច្នេះឃើញហើយ អចិន្ត្រៃយ៍មជ្ឈិមលែងជឿទុកចិត្ត ណាត ហើយ នៅក្នុងឯកសារនេះ ។

[១១:២៦:៣០]

បើប្រៀបធៀបទៅនឹងឯកសារ ថ្ងៃ៩ តុលា ១៩៧៥ ពីដើមមក ប៉ុល ពត មិនជឿទុកចិត្តតែ ចក្រី ទេ ឥឡូវប៉ុល ពត មិនជឿទុកចិត្ត ណាត ទៅទៀត ។ ខ្ញុំសូមអានបញ្ហានេះ ពីដើមមក ប៉ុល ពត សរសើរណាស់កងពល១២ កងពល១២នេះ ជាឈ្មោះចាស់របស់កងពល៧០៣ គាត់សរសេរថា-- គាត់មានប្រសាសន៍ថា "មាគ៌ាប្រយុទ្ធកងពល១២ ពូកែណាស់" ដល់ពេលនិយាយពី ណាត និង ចាន់ ចក្រី អ៎!ជាពិសេសដល់ពេលនិយាយពីចាន់ ចក្រី បើយើងក្តាប់គេមិនបាន ឲ្យគេមកធ្វើការនៅក្នុងសេនាធិការ។ ឧទាហរណ៍ មិត្តមាន មិត្តមានហ្នឹង គឺចាន់ ចក្រី អាចមកខាងយោធា-- អាចមកខាងនយោបាយ ឬខាងយោធា ហើយជ្រើសរើសសមមិត្តណាម្នាក់ឲ្យធ្វើលេខាកងពល ។ ដូច្នេះ ពីថ្ងៃ៩ ខែតុលា ១៩៧៥ ប៉ុល ពត សរសើរណាស់កងពល១២របស់ ណាត ។ ៦ខែ ១០ថ្ងៃ បន្ទាប់មក ណាត ហើយនិង ចាន់ ចក្រី ត្រូវបក្សសង្ស័យដូចគ្នា ។ សរុបមកប៉ុណ្ណឹង ឃើញហើយ ឃើញថាបក្សមិនជឿទុកចិត្ត ណាត ដកការងារជាបណ្តើរៗ ។ នេះខ្ញុំសូមសរុបជូនប៉ុណ្ណេះ សូមបញ្ចប់។

**ស៖** សូមអរគុណ ។ អ៊ីចឹងខ្ញុំចាប់ផ្តើមសួរសំណួរទី៩ ។ កន្លងមកតាមខ្ញុំស្តាប់ លោកពន្យល់ ខ្ញុំសន្និដ្ឋានថា អ្នកដែលមានសិទ្ធិសម្រេចកម្ទេចមានតែពួកបួនក្រុម គឺអចិន្ត្រៃយ៍មជ្ឈិម លេខាភូមិភាគ លេខាគណៈមន្ទីរមជ្ឈិម និងលេខាសេនាធិការ ។ តើលោកយល់ស្របនឹងខ្ញុំទេ?

តទៅទៀត អ្នកដែលគ្មានសិទ្ធិសម្រេចកម្ទេចដូច ណាត ដូច កុយ ធួន ដែលគេចាប់កន្លងមក តែគាត់សម្រេចកម្ទេច ពិតជាត្រូវបក្សមានវិធានការជាបន្តបន្ទាប់ តើលោកយល់ស្របនឹងខ្ញុំទេ?

**ឆ៖** អរគុណ ខ្ញុំយល់ស្រប ។

**ស៖** អ៊ីចឹង បើតាមលោក លោកមានសេចក្តីសន្និដ្ឋានប្លែកពីខ្ញុំយ៉ាងម៉េចដែរ ចំពោះនេះ? សូមឲ្យខ្លី?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! សេចក្ដីសន្និដ្ឋានរបស់លោកទាំងពីរចំណុចនេះ ខ្ញុំឯកភាព ហើយខ្ញុំសូមជូនសេចក្ដីសន្និដ្ឋានរបស់ខ្ញុំ ដោយបែងចែកប្រវត្តិនៃការអនុវត្តមាគ៌ានៅក្នុងស-២១ ជាពីរដំណាក់កាល ។ ដំណាក់កាលទី១ គឺពេលដែល ណាត ធ្វើប្រធាន ។ វាមានរឿងច្របូកច្របល់អ៊ីចឹងជាពិសេសចាប់មនុស្សដោយអត្តនោម័តិ ហើយតាំងកាយកប់លុបដានថាដោះលែង ការពិតអត់ដោះលែងទេ ដោះលែងក្លែងក្លាយ ។ ទីពីរ នៅពេលដែលខ្ញុំធ្វើជាប្រធាន ការសម្រិតសម្រាំងអង្គភាពឈរលើគោលការណ៍ពីរ គឺឯកភាពគ្នាដោយស្មោះអស់ពីចិត្តនៅក្នុងគណៈកម្មាធិការស-២១ គឺរវាងលេខា និងអនុលេខា រួចហើយយើងខ្ញុំសុំការអនុម័តអំពីអចិន្ត្រៃយ៍ ។ ឧទាហរណ៍ឯកសារES Annex C18.81 ដែលយើងខ្ញុំចារលើប្រវត្តិរូបរបស់ មុត ហេង ក្រោយពីបានទទួលសេចក្ដីសម្រេចពីអចិន្ត្រៃយ៍ ។

ទីពីរ ក្នុងករណីសង្ស័យ យើងខ្ញុំឯកភាពគ្នាជាពិសេសដើម្បីផ្ទេរយុទ្ធជនខ្លះ ពីអង្គភាពសួរចម្លើយទៅជាយុទ្ធជននៅព្រៃស មានឈ្មោះមិត្តឈុន ធំ នៅក្នុងឯកសារE5/2.34 ត្រង់ទំព័រ ERN 00228010 ជាដើម ។ ពេលណាមានចម្លើយឆ្លើយដាក់ចំមនុស្សដែលនៅក្នុងអង្គភាព យើងខ្ញុំក៏បង្កើនវិធានការប្រុងប្រយ័ត្នការពារយថាហេតុ ដើម្បីសុំសេចក្ដីសម្រេចពីអង្គការនៅពេលណាដែលចាំបាច់ ។ ឧទាហរណ៍មាននៅក្នុងឯសារ E5/2.52 ត្រង់ទំព័រ 00226779 ជាឧទាហរណ៍ស្រាប់ យើងខ្ញុំមិនដែលហ៊ានអនុម័តចាប់មនុស្ស ដោយមិនបានទទួលសេចក្ដីសម្រេចពីអចិន្ត្រៃយ៍មជ្ឈិមទេ ។ នេះសូមបញ្ចប់ប៉ុណ្ណេះ សូមអរគុណ ។

[១១:៣២:០៦]

**ស៖** សូមអរគុណ ខ្ញុំសូមសួរបីសំណួរទៀត ។ ក្នុងចំណោមមនុស្ស១២.៣៨០នាក់ ដែលត្រូវបានកម្ទេចនៅ ស-២១ ។ តើមានប៉ុន្មាននាក់ ដែលលោកបានកម្ទេចផ្ទាល់ដៃរបស់លោក?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំសូមបញ្ជាក់ម្ដងទៀតថា ខ្ញុំទោះបីនៅម-១៣ ក៏ដោយ មកដល់ ស-២១ ក៏ដោយ មិនដែលបានកម្ទេចអ្នកណាម្នាក់ដោយផ្ទាល់ទេ ។ សូមចប់ ។

**ស៖** សូមអរគុណ ។ លោកថា លោកមិនដែលមានកម្ទេចអ្នកណាម្នាក់ ដោយផ្ទាល់ដៃទេ ចុះហេតុអ្វីក៏លោកព្រមទទួលយកនូវឧក្រិដ្ឋកម្មទាំងអស់នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ឧក្រិដ្ឋកម្មទាំងអស់ វាកើតចេញអំពីមាគ៌ាបក្សកុម្មុយនីស្តកម្ពុជា ។ ខ្ញុំជាបក្ខជនមួយរូប ដែលគេប្រគល់ទៅឲ្យកាន់កាប់ស-២១ យន្តការឧក្រិដ្ឋរបស់បក្សនេះទៅលើជីវិតមនុស្ស១២.៣៨០នាក់ យ៉ាងតិច ។ ដូច្នេះ អ្នកណាហ៊ានមិនធ្វើតាមមាគ៌ានេះ អ្នកនោះត្រូវ

ប្រឈមមុខជាមួយនឹងខ្ញុំជាមុន គឺអ្នកឯងត្រូវខ្ញុំរាយការណ៍ អ្នកឯងត្រូវខ្ញុំស្នើសុំចាប់ ។ ដូច្នេះ ខ្ញុំជាម្ចាស់នៅលើទីនោះ ដើម្បីឲ្យគេអនុវត្តមាគ៌ាឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ទៅលើមនុស្ស ខ្ញុំទទួល ពីព្រោះបើគ្មានខ្ញុំសម្រាប់ជាគោលរបស់បក្ស ដើម្បីឲ្យគេអនុវត្តធ្វើតាមទេ វា១ បញ្ជាវាទៅផ្សេងទៅវិញ ។ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

**សៈ** សូមអរគុណ។ លោកជាអ្នកបញ្ជាទៅថ្នាក់ក្រោមរបស់លោក ដើម្បីឲ្យកម្ទេចជនរងគ្រោះទាំង១២.៣៨០ នាក់ អ៊ីចឹងថ្នាក់លើរបស់លោកមានបញ្ជាលើលោកយ៉ាងណាខ្លះ? អ្នកណាខ្លះ? សូមលោកបញ្ជាក់ជូនតុលាការឲ្យអស់ថា ថ្នាក់លើរបស់លោក មានអ្នកនេះៗដែលបញ្ជាលើលោក ដើម្បីឲ្យមហាជនទូទាំងប្រទេស ក៏ដូចជាសាកលលោក គេឃើញ គេយល់ គេដឹងពីមុខឧក្រិដ្ឋជនទាំងនោះ?

**ឆៈ** ជម្រាបប្រសាសន៍លោកមេធាវី! មាគ៌ាបក្ស ខ្ញុំបានរាយការណ៍ជូនអង្គសវនាការយើងហើយ ឲ្យតែខ្មាំងគឺត្រូវតែកម្ទេច ឲ្យតែមិត្ត គឺត្រូវតែដោះលែង ។ នេះជាមាគ៌ាដែលប្រចាំ គ្មានអ្នកណា--សូមទោស ខ្ញុំសុំនិយាយឡើងវិញ ។ ឲ្យតែមិត្ត គឺត្រូវតែឧបត្ថម្ភ ឧបត្ថម្ភគ្រប់បែបយ៉ាង នេះជាមាគ៌ាបក្សដែលគ្មាននរណាហ៊ានល្មើសបាន ។ ដូច្នេះ អ្នកណាក៏គោរព ប៉ុល ពត ខ្លួនឯងក៏គោរព អ្នកក៏គោរពដែរ មិនហ៊ានឲ្យល្មើស នេះជាមាគ៌ាបក្ស ។ ក៏ប៉ុន្តែ អ្នកដែលបញ្ជាផ្ទាល់ ចាត់ចែងកិច្ចការផ្ទាល់ពីលើខ្ញុំគ្រប់ពេលវេលា ដំបូងគឺលោកគ្រូ សុន សេន មេខ្ញុំ បន្ទាប់មកគឺ ពូនួន គឺ នួន ជា នេះឯងដែលបញ្ជាពីលើខ្ញុំ ឧទាហរណ៍ ឯកសារ D159/2.10 ដែលបញ្ជាឲ្យខ្ញុំកម្ទេចពួក៩២០ អង្គភាព៩២០ ទាំងមួយរយនាក់នេះ គឺ ពូ នួន គាត់បញ្ជាមក ។ ដូច្នេះ ខាងលើកុំប្រកែកណ៎ា ត្រូវធ្វើឲ្យខ្ញុំ ព្រោះបញ្ជាពីលើមក ខ្ញុំល្មើសមិនបានទេ អ្នកឯងល្មើសនឹងខ្ញុំ ខ្ញុំរាយការណ៍ អ្នកឯងស្លាប់ ។ នេះគឺអ៊ីចឹង សុំបញ្ជាក់ជូនប៉ុណ្ណេះ ។

**សៈ** សូមអរគុណ ។ សូមលោកបញ្ជាក់ថែមទៀត អំមិញថៅហ្វាយរបស់លោក គឺមាន សុន សេន និង នួន ជា អ្នកបញ្ជាលោកឲ្យទៅ បញ្ជាតទៅទៀតដើម្បីកាប់សម្លាប់ ។ អ៊ីចឹងអ្ហើ អ្នកណាបញ្ជាលើ នួន ជា បញ្ជាលើ សុន សេន មានទៀតទេ សូមលោកបញ្ជាក់ឲ្យអស់ កុំទុក ។

**ឆៈ** ឪម៉ែអាធំជាងគេគឺ ប៉ុល ពត គ្មានអ្នកណាធំជាង ប៉ុល ពត ទេ នេះខ្ញុំសុំបញ្ជាក់ជូនប៉ុណ្ណេះឯចំណែក ទៅតាមភូមិភាគវាផ្សេង វាបែកសាខាទៅតាមនុ៎ង ដូចមានចែងនៅក្នុងឯកសារថ្ងៃ៣០ មីនា ១៩៧៦ ហើយ ។ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

**សៈ** សំណួរចុងក្រោយ លោកជាប្រធានស-២១ តើលោកធ្លាប់ធ្វើទារុណកម្មផ្ទាល់ដៃដល់អ្នកទោសអស់ប៉ុន្មាននាក់ក្នុង១២.៣៨០នាក់ដែលស្លាប់ហ្នឹង លោកធ្វើទារុណកម្មផ្ទាល់ដៃមានទេ? ប៉ុន្មាននាក់?

**ឆៈ** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំនិយាយនេះក្នុងនាមចាំច្បាស់លាស់ អត់ន័យថា បើសិនជាខ្ញុំមិនច្រឡំទេ គឺចាំច្បាស់លាស់ ខ្ញុំធ្វើទារុណកម្មទៅលើ ឈិត អ៊ីវ តែម្នាក់គត់ ។ នេះសូមបញ្ចប់ប៉ុណ្ណេះ គឺនៅពេលដែលខ្ញុំធ្វើអនុលេខានៅឡើយទេ ខ្ញុំនៅជាអនុលេខា ។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ សូមឲ្យលោកមេធាវី ហ្វ្រង់ស្វ័រ បន្តសំណួរតទៀត សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

[១១:៣៩:០០]

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមអរគុណផងដែរដល់ភាគីទាំងអស់ដែលបានព្រមព្រៀងឲ្យលើកការប្រជុំរៀបចំសវនាការមករសៀលនេះ ។ ហើយនៅក្នុងដំណាក់កាលនេះ ខ្ញុំមានសំណួរតែពីរបីប៉ុណ្ណោះ ។

**សៈ** ឌុច នៅពេលដែលមេធាវីរបស់លោកស្នើទៅសហចៅក្រមស៊ើបអង្កេតថា ការរៀបចំធ្វើការសម្តែងឡើងវិញនៅ ស-២១ និងនៅជើងឯកនោះ លោកបានឯកភាពចូលរួមនៅក្នុងការសម្តែងឡើងវិញនោះ ។ តើត្រឹមត្រូវដែរឬទេ?

**ឆៈ** ជម្រាបលោកមេធាវី ខ្ញុំៗយល់ស្របទៅដោយស្ម័គ្រចិត្តពិតប្រាកដមែនអង្កាល់ណោះ ។

**សៈ** ហើយនៅខែកុម្ភៈ ឆ្នាំ២០០៨ នៅព្រឹកមួយនោះ គឺសាមសិបឆ្នាំក្រោយពីព្រឹត្តិការណ៍បានកើតឡើង លោកបានត្រលប់ទៅស-២១វិញ គឺមន្ទីរស-២១ ដែលលោកបានចាកចេញ កាលពីខែមករា ឆ្នាំ១៩៧៩ នោះ ។ តើត្រឹមត្រូវដែរឬទេ?

**ឆៈ** ជម្រាបលោកមេធាវី! ខ្ញុំបានទៅដល់ស-២១ ប៉ុន្តែមុនទៅដល់ស-២១ ខ្ញុំទៅដល់ជើងឯក ។ ជើងឯកពីមុនមក ខ្ញុំទៅបានតែម្តងទេ ហើយមួយភ្លែត ។ ដល់ខ្ញុំទៅជើងឯក វារន្ធត់ម៉្យាងហើយ ទៅឃើញកន្លែងដែលមនុស្សស្លាប់ ទៅជើងឯកនេះ ខ្ញុំបានសារភាពជូនជាតិប្រជាជនខ្ញុំថា កុមារប្រហែលជាអាចត្រូវគេបោកក្បាលសម្លាប់ ។ ទន្ទឹមនេះ នៅនឹងរោងសម្រាប់បិតអីៗហ្នឹង ខ្ញុំឃើញរូបថត លោកសាស្ត្រាចារ្យ ភីង តុន ដែលពីដើមមកខ្ញុំមិនជឿថា គាត់ធ្លាក់ខ្លួនមកដល់ ស-២១ ដល់ឃើញ ខ្ញុំចប់ៗ ឃើញរូបថតគាត់ច្បាស់ក្រឡែតនឹងភ្នែកនេះ ខ្ញុំឃើញអក្សរគាត់សរសេរនៅក្នុងប្រវត្តិរូប ។ អ៊ុយ! អត់

*វើគើនុយ* ទេ ខ្ញុំឃើញៗអក្សរគាត់ដែលសរសេរនៅក្នុងប្រវត្តិរូប ។ ខ្ញុំមិនដែលអាន មិនដែលឃើញអក្សរគាត់ទេ ប៉ុន្តែជឿថា អក្សរគាត់ ។ ដល់ពេលហ្នឹង ពាក្យដែលខ្ញុំប្រកែកថា ខ្ញុំ លោកគ្រូ ភីង គុន មិនទៅរងគ្រោះនៅស-២១ ខ្ញុំលែងហ៊ានប្រកែកទៀតហើយ ការពិតវាមកហើយ ។ វានៅតែចោទបញ្ហាថា ម៉េចបានជាខ្ញុំមិនដឹង នេះបញ្ហាទីពីរ ។

[១១:៤៣:១៤]

ដល់ទីបី ខ្ញុំនឹកឡើងវាខ្លោចចិត្តនឹងរឿងអាយុជីវិតមនុស្សដែលស្លាប់នៅជើងឯក ។ ដូច្នេះ តម្រូវឲ្យខ្ញុំអធិដ្ឋានព្រះជាម្ចាស់ ដើម្បីវិញ្ញាណក្ខន្ធអ្នកអស់នោះ ។ ដល់មកដល់ស-២១ ខ្ញុំឃើញសភាពការណ៍គួរឲ្យតក់ស្លុតច្រើនណាស់ ឃើញជនរងគ្រោះ ដែលនៅរស់មានជីវិត៣នាក់ មកចំពោះមុខខ្ញុំអនុស្សាវរីយចាស់ទាំងប៉ុន្មាន វាលេចធ្លោឡើង ។ អនុស្សាវរីយមួយទៀតគឺ រូបថតស្ត្រីដែលបីកូននោះ ក៏លេចធ្លោឡើង ធ្វើឲ្យខ្ញុំទ្រាំអត់បានទេ ខ្ញុំមានការក្តុកក្តួលចំពោះមុខជនរងគ្រោះដែលនៅរស់ ។ ខ្ញុំបានធ្វើវិយោគកថាមួយ ចំពោះវិញ្ញាណក្ខន្ធអ្នកដែលស្លាប់ទៅ ។ នេះខ្ញុំនៅចាំមិនភ្លេចទេ រឿងរ៉ាវទាំងអស់នេះ ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ពីការដែលខ្ញុំបានទៅជើងឯក ហើយនិងស-២១ មជ្ឈមណ្ឌលភ្នំពេញ ។

រឿងរ៉ាវដែលគួរឲ្យតក់ស្លុតនៅស-២១ច្រើនណាស់ នៅស-២១មជ្ឈមណ្ឌលភ្នំពេញ តែខ្ញុំសូមសង្ខេបខ្លីប៉ុណ្ណេះចុះ ។

[១១:៤៥:៥៥]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន នៅក្នុងពេលនេះក្រុមមេធាវីការពារក្តី សូមស្នើឲ្យធ្វើការចាក់បញ្ចាំងខ្សែភាពយន្តខ្លីមួយ ដែលមានរយៈពេលតែបីនាទីប៉ុណ្ណោះ ដែលស្តីអំពីការសម្តែងឡើងវិញ ។ ហើយខ្ញុំចង់បញ្ជាក់ថា មិនមានសាក្សី ឬក៏ជនរងគ្រោះ មាននៅក្នុងខ្សែភាពយន្តនោះទេ គឺមានតែជនជាប់ចោទតែប៉ុណ្ណោះ ។ ហើយខ្ញុំចង់រំឭកថា ការថតខ្សែភាពយន្តនៃការសម្តែងឡើងវិញទាំងអស់នោះ គឺត្រូវបានធ្វើឡើងទៅតាមសំណើរបស់ខាងសហចៅក្រមស៊ើបអង្កេត ។ ហើយការដកស្រង់នោះ គឺបង្ហាញនៅពេលដែល ឌុច ចង់និយាយនៅចំពោះមុខជនរងគ្រោះ ហើយគាត់មិនអាចបន្តបានទៀតទេ ។ ហើយនៅពេលដែលលោកពិនិត្យមើលហើយ ទើបដឹងថាហេតុផលអ្វីបានជាដូច្នេះ ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី មានអត្ថសញ្ញាណនៃឌីស នៃឯកសារហ្នឹងទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

បាទ គឺមាន គឺ D48.2 ។

**ប្រធានអង្គជំនុំ៖**

ខាងផ្នែកសោតទស្សន៍ ។

[១១:៤៩:១០]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ លោកប្រធាន ថាតើប្រតិចារឹកនៃអ្វី ដែលនឹងត្រូវបានបញ្ចាំងនៅលើខ្សែភាពយន្ត នោះត្រូវបានចែកជូនឲ្យអ្នកបកប្រែហើយឬនៅ? តើអាចផ្ដល់ចម្លើយនេះប្រាប់ខ្ញុំទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកស្រីចៅក្រម គឺតាមពិតទៅមានការនិយាយតែបន្តិចបន្តួចតែប៉ុណ្ណោះ នៅក្នុងចំណុចនេះ ហើយអ្វីដែលបាននិយាយនោះ គឺត្រូវបាននិយាយជាភាសាខ្មែរ និងភាសាបារាំង ។

[១១:៥០:០៣]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

នៅក្នុងករណីនេះ គឺយើងអាចបន្តការបង្ហាញនូវការដកស្រង់នៃខ្សែភាពយន្តនេះ ប៉ុន្តែបើសិនជាអ្នកបកប្រែមានបញ្ហាគឺយើងនឹងអាចដោះស្រាយនៅពេលដែលមានរឿងកើតឡើងនោះ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ដែលចាប់បញ្ចាំងនៅខ្សែវីដេអូដែលមានD48.2 បានទេ?

[១១:៥០:៣៩]

*[ខ្សែវីដេអូអំពីការថ្លែងសុន្ទរកថាខមាទោសដំបូងរបស់ ឌុច ចំពោះមុខជនរងគ្រោះនៅទួលស្លែង ពី១១:៥០:៥៧នាទី រហូតដល់ ១១:៥០:៥៧នាទី]*

***[ជនជាប់ចោទ៖***

*សូមអានសេចក្ដីបញ្ជាក់ ។*

*លោកចៅក្រមទាំងពីរជាទីគោរព! ខ្ញុំរន្ធត់ក្នុងចិត្តឥតឧបមា នៅពេលដែលបានឈានជើងចូលមកដល់ទីនេះ ស្ថានទីដ៏មហាខ្លោចផ្សាបំផុតសម្រាប់ជាតិប្រជាជនខ្ញុំ-- (អ្នកបកប្រែស្ដាប់សំឡេងអត់ឮទេ) ក៏ដូចសម្រាប់រូបខ្ញុំដែរ ។*

*ទីមួយ ខ្ញុំនឹកទៅដល់ជនរងគ្រោះដ៏អភ័ព្វនិងក្រុមគ្រួសាររបស់គេ ។ គេទាំងឡាយបានរងទុក្ខវេទនា រងទារុណកម្ម រងការប្រមាទមើលងាយដ៏សែនអមនុស្សធម៌រាប់មិនអស់ មុននឹងបាត់បង់ជីវិតរលត់សង្ខារទៅ ។ ខ្ញុំមានវិប្បដិសារី--*

*(ជនជាប់ចោទយំ)*

***លោក យូ ប៊ុនឡេង៖***

*នៅក្នុងនេះ ដែលមេធាវីខាងជនជាប់ចោទគាត់សុំអាននៅក្នុងដំណាក់កាលដំបូង ។ សាក្សី និងជនរងគ្រោះមិនទាន់បានចង្អុលបង្ហាញនេះ ឃើញថា-- ខ្ញុំគ្រាន់តែចង់សួរយោបល់ទៅខាងលោកមេធាវីខាងជនរងគ្រោះនោះ ដែលជាដើមបណ្ដឹងរដ្ឋប្បវេណី តើលោកយល់ថាយ៉ាងម៉េចដែរ? ហើយបើសិនជាឲ្យ-- សុំឲ្យផ្ដល់យោបល់មកខាង-- (បកប្រែភាសាបារាំង)*

*ហើយក្នុងនេះគឺខ្ញុំសូមឲ្យព្រះរាជអាជ្ញា ជាភាគីមួយដែរ តើលោកមានយោបល់អីដែរអត់?*]

[១១:៥៤:៣២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធានការបញ្ចាំងនោះគឺត្រឹមត្រូវគ្រប់គ្រាន់ត្រឹមនេះហើយ ។ ហើយខ្ញុំមានសំណួរមួយចុងក្រោយទៀតដើម្បីសួរទៅជនជាប់ចោទ ។ ខ្ញុំចង់ធ្វើការបង្ហាញឲ្យបានច្បាស់ថា សេចក្ដីថ្លែងរបស់ជនបជាប់ចោទ គឺការអានចនូវសេចក្ដីថ្លែងការណ៍នោះត្រូវបានបញ្ឍប់នូវដំណាក់កាលដំបូងនៃការធ្វើឡើងវិញ នៃការសម្ដែងឡើងវិញនោះ ។ ហើយបន្ទាប់មកទៀត គឺយើងមានដំណាក់កាលមួយទៀតនៃខ្សែភាពយន្តដែលគាត់បានអានពេញគឺដែលធ្វើឡើងនៅវសៀលនៃការសម្ដែងឡើងវិញនៅថ្ងៃនោះ ។ ហើយនៅពេលនោះ គឺជនជាប់ចោទបាននិយាយជាមួយនឹងជនរងគ្រោះ ហើយយើងសូមធ្វើការបង្ហាញនូវផ្នែកនេះនៅពេលដែលសាក្សី-- ជនរងគ្រោះទាំងហ្នឹងបានផ្ដល់សក្ខីកម្មរួច ។ អ៊ីចឹង លោក ឌុច នៅពេលដែលលោកបានមើលខ្សែភាពយន្តនេះហើយ ខ្ញុំមានសំណួរមួយទៀតដើម្បីសួរលោក ។ ហើយវាជាសំណួរចុងក្រោយ ។

ចាប់តាំងពីមានវិសោកនាដកម្មដែលកើតមានឡើងនៅស-២១ នោះមក តើលោកធ្លាប់បានធ្វើការបួងសួងដល់វិញ្ញាណខន្ធរបស់អ្នកដែលបានរងគ្រោះនោះដែរ ឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ឆ្នាំ១៩៧៥ វាជារឿងរន្ធត់មួយដែលយើងខ្ញុំខំគេច ។ ឆ្នាំ១៩៧៩ គេចយ៉ាងម៉េចក៏វានៅតែឃើញដែរ ។ ឃើញការស្លាប់និរាសព្រាត់ប្រាស់ ចុងបញ្ចប់ វាស្លាប់ទៅទាំងអស់នៅអង្គភាពស-២១ ចាស់ អង្គភាពខ្ញុំមែនអង្គភាព ស-២១ នេះទៀតទេ ។ គ្មានសល់ទេ មានអ្នកខ្លះរត់បានមកដល់ផ្ទះសម្បែងវិញ ក៏ប៉ុន្តែភាគច្រើនស្លាប់ ។ ស្លាប់ទាំងប្អូនខ្ញុំ ស្លាប់ទាំងក្មួយខ្ញុំ ស្លាប់ទាំងប្រពន្ធបង ម៉ម ណៃ ស្លាប់ទាំងប្រពន្ធ មិត្តប៊ុន ធ្វើឲ្យខ្ញុំនិរាសព្រាត់ប្រាស់នៅកណ្តោចកណ្តែងតែម្នាក់ឯងជាមួយនឹងប្រពន្ធហើយនិងកូនពីរនាក់ ។ នៅពេលនុ៎ង ខ្ញុំគិតអណោចអាធ័មម៏កាន់តែខ្លាំង ។ ប្រពន្ធខ្ញុំដឹងយ៉ាងម៉េចទេ កាលណោះ គាត់មកប្រាប់ខ្ញុំថា គាត់ប៉ុន្មានថ្ងៃហ្នឹង វានឹកដល់ខ្មោចឪពុកខ្ញុំដល់ហើយ ។ ខ្ញុំថាមានអី ហើយទទួលខ្ញុំកំពុងតែក្តុកក្តួលស្រាប់ មានអីអញក៏នឹកដល់គាត់ដែរ ។ រួចប្រពន្ធខ្ញុំគាត់សួរថាម៉េចអ៊ីចឹង ខ្ញុំថាសែនៗ ។ ប្រពន្ធខ្ញុំសួរថា សែនយ៉ាងម៉េចបើយើងអត់ដឹងថាគាត់ខូចហើយឬក៏នៅរស់នៅឡើយផង ។ កុំគិតអ៊ីចុង ។ យើងសែនមើលថ្ងៃកំណើតរបស់ខ្ញុំ ដើម្បីសុំទោសឪពុកខ្ញុំដែលផ្តល់កំណើតដល់ខ្ញុំគឺនៅថ្ងៃ១៧ វិច្ឆិកា ឆ្នាំ១៩៧០ (សូមទោស) ១៩៤២ ដែលលោកខំបង្កើតខ្ញុំមកឲ្យធ្វើល្អចំពោះមនុស្សទូទៅ ចំពោះជាតិប្រជាជនកម្ពុជា តែខ្ញុំបែរជាធ្វើខុស ។ ម្ល៉ោះហើយ ខ្ញុំក៏សែនរាល់ឆ្នាំរហូតៗ ។ មុនដំបូង សែនសុំទោសឪពុកម្តាយ ក្រោយមកសុំទោសគ្រូបាអាចារ្យ មានព្រះសង្ឃកុដលេខបី ព្រះនាម ប្រាជ្ញ ប៉ុល នេះ មានសុំទោស បងវន សុំទោស បងហុក ដល់យូរៗទៅសុំទោសជនរងគ្រោះទាំងអស់ទូទាំងប្រទេសរាល់វេលា គ្រប់ពេលវេលា អត់ដែលខានទេ ។ រហូតនៅពេលដែលខ្ញុំជាប់គុក វាអត់មានលទ្ធភាពនឹងសែនទេ ប៉ុន្តែថ្ងៃ១៧ វិច្ឆិកា ឆ្នាំ១៩៧០ (សូមទោស) ថ្ងៃ១៧ វិច្ឆិកា គ្រប់ៗឆ្នាំខ្ញុំមិនដែលបានធ្វើអីកើតទេ ថ្ងៃនោះ ត្រូវតែមានធ្វើអីបន្តិចដើម្បីរំឭកដល់វិញ្ញាណខន្ធដល់ជនរងគ្រោះ ។ នេះមួយបែប ។

[១១:៥៩:៤៧]

មួយបែបទៀត នៅគ្រប់ពេលដែលខ្ញុំអធិដ្ឋានព្រះជាម្ចាស់ នៅពេលដែលខ្ញុំជឿដល់ព្រះយេស៊ូហើយ ខ្ញុំអ្នកអធិដ្ឋានដល់ព្រះរាជាម្ចាស់ ខ្ញុំតែងនឹកដល់វិញ្ញាណក្ខន្ធជនរងគ្រោះទាំងអស់ជានិច្ច ។ នេះខ្ញុំសូមបញ្ជាក់ ថាខ្ញុំអធិដ្ឋានគ្រប់ពេលវេលា ខ្ញុំអត់ដែលខានទេ ។ នេះខ្ញុំសូមបញ្ចប់បញ្ហានេះប៉ុណ្ណេះ ។ ហើយនៅចុងបញ្ចប់នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធាននិយាយឲ្យចំបញ្ហាមួយ គឺបញ្ហាលោកគ្រូ ភីង គុនជាអ្នកបង ហើយនិងអ្នកស្រី ស៊ុនថារី ជាបុត្រីលោកនៅទីនេះ ។ បើសិនលោកប្រធានអនុញ្ញាត ខ្ញុំសូមនិយាយបញ្ហានេះ ។

**ប្រធានអង្គជំនុំ៖**

បានហើយនៅមានឱកាសចុងក្រោយទៀត ដែលលោកនឹងអាចសម្តែង មិនមាននៅដែលពេលនេះទេ គឺនៅមានពេលចុងក្រោយនៃបញ្ចប់ដំណើរការនោះ គឺមុននឹងធ្វើ-- បិទនោះគឺយើងនឹងផ្តល់ឱកាសជូនសទៅលោក ដើម្បីឲ្យលោកនិយាយចុងក្រោយទៅកាន់ជនរងគ្រោះ គ្រួសារជនរងគ្រោះ ប្រជាជនកម្ពុជា ក៏ដូចជាមនុស្សជាតិនៅលើពិភពលោក ។ មុននឹងតុលាការបិទការដេញដោលឈានដល់ពិចារ-ណាសម្រេចសេចក្តី។ អ៊ីចឹង គឺពេលនេះយើងមិនបន្តការអនុញ្ញាតឲ្យលោកធ្វើកិច្ចការនេះទេ ។

លោកមេធាវី តើមានអ្វីទៀតទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំអស់សំណួរហើយលោកប្រធាន សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ។ ហើយឥឡូវនេះក៏ដល់ពេលត្រូវពិសារអាហារថ្ងៃត្រង់ហើយ ប៉ុន្តែមុននឹងឈប់សម្រាកនេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់សាធារណជននិងអ្នកសារព័ត៌មានថា នៅរសៀលនេះ អង្គជំនុំជម្រះសាលាដំបូងនឹងដំណើរការប្រជុំរៀបចំសវនាការដែលត្រូវធ្វើជាអសាធារណៈ ដែលមិនអនុញ្ញាតឲ្យសាធារណជននិងសារព័ត៌មានចូលរួមនៅក្នុងដំណើរការនោះទេ ។ ជាការងារពិភាក្សាបច្ចេកទេសដើម្បីរិះរកមធ្យោបាយចំណាត់ការរឿងក្តីនេះឲ្យបានឆាប់រហ័សប៉ុណ្ណោះ ។ អ៊ីចឹងសូមជ្រាប ។ ហើយអង្គជំនុំជម្រះសូមប្រកាសសម្រាក ដើម្បីពិសារអាហារថ្ងៃត្រង់ ហើយអង្គជំនុំជម្រះនឹងចាប់បន្តនូវនៅកិច្ចប្រជុំសវនាការរបស់ខ្លួនចាប់វេលាម៉ោងមួយនិងសាមសិបនាទីរសៀលនេះ ។ ដូច្នេះ សូមភាគីទាំងអស់ជ្រាប ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី ៕

*[អង្គសវនាការផ្អាកនៅម៉ោង ១២:០៣ នាទី]*